วิวิตฺตานิ ปวิวิตฺตานิ ฯ สพฺพ ยญฺหิ ภณฺฑ ตถาคตสฺส ปริโภคารหตาย ปณีตปจฺจยสฺส ปฏิคฺคหณโตปิ มหาโต ภควาโต สพฺพสฺมาปิ วิเวจน วิวิตฺตตร นตฺถิ ตสฺมา ภควาโต สพฺพสฺมาปิ วิเวกา ปวิวิตฺตตรตฺตา ปวิวิตฺตานิ วิวิตฺตานิ อปิจ ภควา วิวิตฺตาย ผลสมาปตฺติยา ผลสมาปชฺชนโต ปวิวิตฺตานิ วิวิตฺตาย กิเลสวิกฺขมฺภนาย ปวิวิตฺตานิ วิวิตฺตาย กิเลสวิกฺขมฺภนาย ปวิวิตฺตานิ วิวิตฺตาย ปฏิปตฺติยา ผลสมาปตฺติยา ปวิวิตฺตานิ วิวิตฺตาย นิพฺพานาธิคมาย ปวิวิตฺตานิ วิวิตฺตาย สพฺพสงฺขารวิวิตฺตาย นิพฺพานาย ปวิวิตฺตานิ ฯ อปิจ ภควา ปวิวิตฺตาย ปวิวิตฺตชนปริวุโต ปวิวิตฺตานิ วิวิตฺตานิ เสนาสนานิ ปฏิสฺเสวติ ฯ อปิจ ภควา ปวิวิตฺตาย ปวิวิตฺตชนปริวุโต ปวิวิตฺตานิ วิวิตฺตานิ เสนาสนานิ ปฏิสฺเสวิตฺวา ปวิวิตฺตาย ปวิวิตฺตชนปริวุโต ปวิวิตฺตาย ปวิวิตฺตชนปริวุตาย ธมฺมเทสนาย ปวิวิตฺตานิ วิวิตฺตานิ ฐานนิสชฺชาทีนิ อธิฏฺฐาย

ព្រះមានព្រះភាគទ្រង់តបថា នែជីវក: តថាគតបានបញ្ចុះថ្នាំហើយ ។ ជីវកកោមារភច្ច ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កាលខ្ញុំព្រះអង្គចេញទៅដល់ក្រៅក្លោងទ្វារហើយ ក៏មានសេចក្តីរំគិត ដូច្នេះថា ថ្នាំបញ្ចុះចំនួន ៣០ ដងគត់ អាត្មាអញបានថ្វាយដល់ព្រះមានព្រះភាគរួចហើយ កាយរបស់ព្រះតថាគត ក្រាស់ដោយទោស ថ្នាំនោះនឹងបញ្ចុះព្រះមានព្រះភាគ ៣០ ដងគត់ក៏ខ្លេ មុខជានឹងបញ្ចុះព្រះមានព្រះភាគបានត្រឹមតែ ២៩ ដង មិ្យ៉ាងទៀត ព្រះដ៏មានព្រះភាគទ្រង់បញ្ចុះថ្នាំរួចហើយមុខជានឹងស្រង់ទឹក ថ្នាំនោះនឹងបញ្ចុះព្រះដ៏មានព្រះភាគដែលស្រង់ទឹករួចហើយម្តងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះដ៏មានព្រះភាគ ៣០ ដងគត់ដោយអាការយ៉ាងនេះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគទ្រង់ស្រង់ទឹកចុះ សូមព្រះសុគតទ្រង់ស្រង់ទឹកចុះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្រង់ទឹកក្តៅហើយ ថ្នាំនោះក៏បានបញ្ចុះព្រះដ៏មានព្រះភាគដែលបានស្រង់ទឹកហើយម្តងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះដ៏មានព្រះភាគ ៣០ ដងគត់យ៉ាងនេះ ។ លោះនោះ ជីវកកោមារភច្ចបានក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស កាយរបស់ព្រះមានព្រះភាគ តាំងនៅជាប្រក្រតីដូចបុរាណហើយ ទើបបានចំរើនដោយដុំព្រះមំសៈដូចបុនោះ ។ លោះនោះ

ភគវតោ ភាយោ ឧច្ចាសទ្ទោ បភាតត្តោ អហោសិ ។

អថខោ ជីវកោ កោមារភច្ចោ តំ សាវេយ្យកំ ទុស្សយុគំ

អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ

និសិន្នោ ខោ ជីវកោ កោមារភច្ចោ ភគវន្តំ ឯតទវោច

ឯតាហំ ភន្តេ ភគវន្តំ វាំ យាចាមីតិ ។ អតិក្កន្តវាក

ខោ ជីវក តថាគតាតិ ។ យញ្ហ ភន្តេ ភគ្គវតំ យញ្ហ

អនវជ្ជន្តិ ។ វនេហិ ជីវកាតិ ។ ភគវា ភន្តេ បំសុកូ-

លិកោ ភិក្ខុសង្ឃោ ច ៩ធំ មេ ភន្តេ សាវេយ្យកំ

ទុស្សយុគំ រញ្ញោ បដ្ឋោគេន បហិតំ ពហុន្នំ ទុស្សានំ

មិនយូរប៉ុន្មានកាយរបស់ព្រះមានព្រះភាគក៏បានជាប្រក្រតីវិញ ។ ១ ណៈនោះ ដីវកកោមារភត្យបានទាំយកសំពត់សិវេយ្យក:(១) ១ គូនោះចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយនៅកន្លែងសមគួរ ។ ដីវកកោមារភត្យអង្គុយនៅ កន្លែងសមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គសូមពរ ១ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា នែដីវក: ព្រះតថាគតភាំងឡាយមានពរកន្លងហើយ ។ ដីវកកោមារភត្យទូលថា សូមទ្រង់ព្រះមេត្តាប្រោស អំពើណាគួរផង មិនមានទោសផង (ខ្ញុំព្រះអង្គសូមចំពោះអំពើនោះ) ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែដីវក: អ្នកចូរនិយាយមកចុះ ។ ដីវកកោមារភត្យទូលថា សូមទ្រង់ព្រះមេត្តាប្រោសព្រះមានព្រះភាគក្តី កិក្ខុសង្ឃក្តី តែងតែទ្រទ្រង់សំពត់បង្សុកូលសូមទ្រង់ព្រះមេត្តាប្រោស សំពត់សិវេយ្យក:១ គូនេះហើយដែលព្រះបាទបង្ហាតបញ្ជូនមកឲ្យខ្ញុំព្រះអង្គ ជាសំពត់លើសលុបប្រសើរជាប្រធាន

---

១ អដ្ឋកថាថា បានដល់សំពត់ដែលគេចោលនៅព្រៃខ្មោច ក្នុងនគរកុរុទ្ធ ។ បានឮមកថាពួកមនុស្សក្នុងនគរកុរុទ្ធបែងរុំសាកសពដោយសំពត់នោះឯងហើយយកទៅចោល ។ មានសត្វបក្សីមានប្រមោយដូចជាវាសំគាល់នូវសំពត់នោះថាជាដុំសាច់ ហើយនាំយកទៅជំកល់ទុកលើកំពូលភ្នំហិមពានន្តរបស់សំពត់នោះចោលចេញវិស្ទើសាច់សពនោះ ។ រំលោះ: ពួកអ្នកដើរព្រៃបានឃើញសំពត់នោះហើយក៏នាំយកមកថ្វាយស្តេច ។ សំពត់នេះហើយដែលព្រះបាទបង្ហោតបានមកដោយហេតុយ៉ាងនេះឯង ។

ตถาหิสฺส ขุรมุณฺฑนาทีนิ ตถาหิสฺส ขุรมุณฺฑนาทีนิ ตถาหิสฺส ขุรมุณฺฑนาทีนิ

ខ្ពស់ខ្លះទៀតវែងជាងសំពត់ដ៏ច្រើន ជាងគូនៃសំពត់ដ៏ច្រើន ជាងរយនៃគូសំពត់ដ៏ច្រើន ជាងពាន់នៃគូសំពត់ដ៏ច្រើន ជាងសែននៃគូសំពត់ដ៏ច្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគទ្រង់ទទួលយកសំពត់សិវេយ្យកៈ ១ គូរបស់ខ្ញុំព្រះអង្គ សូមទ្រង់អនុញ្ញាតគហបតិចីវរ ដល់ភិក្ខុសង្ឃផង ។ ព្រះមានព្រះភាគ ត្រមទទួលយកសំពត់សិវេយ្យកៈ ១ គូ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ពន្យល់ដឹកនាំ ញុះញង់ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ ដឹកនាំញុះញង់ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយថយចេញទៅ ។ ព្រោះនិទានេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគហបតិចីវរ ភិក្ខុណាប្រាថ្នា (បង្សុកូល) ភិក្ខុនោះចូរទ្រទ្រង់សំពត់បង្សុកូលចុះ ភិក្ខុណាប្រាថ្នា (គហបតិចីវរ) ភិក្ខុនោះចូរត្រេកអរនឹងគហបតិចីវរចុះ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត តថាគតពោលសរសើរសេចក្តីសន្តោសដោយបច្ច័យណាមួយ (តាមមានតាមបាន) ។

[๘๒] อเสฺสาสุ โข ภควโต มยฺหุเสฺสาโก ภควตา สทฺธึ สกฺขินา สหายตาปีติ อนุญฺญาตนฺติ ฯ เต จ มยฺหุเสฺสาโก หาฏา อโหสุ ขุชฺชา ๙ธาติ โข มยิ ฆานาติ ธเสฺสาม ปุญฺญานิ กริสฺสาม ยาโว ภควตา สทฺธึ สกฺขินา สหายตาปีติ อนุญฺญาตนฺติ ฯ ปกาโหเนว ภควโต ๓หฺยาติ ปิวสหสฺสานิ ขุปฺปฏฺฐึสุ ฯ อเสฺสาสุ โข ฉาฬมฺหา มยฺหุเสฺสาโก ภควตา สทฺธึ สกฺขินา สหายตาปีติ อนุญฺญาตนฺติ ฯ เต จ มยฺหุเสฺสาโก หาฏา อโหสุ ขุชฺชา ๙ธาติ โข มยิ ฆานาติ ธเสฺสาม ปุญฺญานิ กริสฺสาม ยาโว ภควตา สทฺธึ สกฺขินา สหายตาปีติ อนุญฺญาตนฺติ ฯ ปกาโหเนว ๘ฉมเทปิ ๓หฺยาติ ปิวสหสฺสานิ ขุปฺปฏฺฐึสุ ฯ

[๘๓] เตน โข ปน สมเยน สมฺพหุลา ภิกฺขู ทกาภเย ขุปฺปฺลาเว ทุพฺภิกฺเข ปจฺจนฺตา ปจฺจนฺตา ๙ตมฺหา อาเวเธสุ ฯ

(៤២) ពួកមនុស្ស ក្នុងក្រុងភគ្គនេះ ចាន់ឮដំណឹងថា ព្រះមាន
ព្រះភាគទ្រង់អនុញ្ញាតគហបតិចីវរដល់ភិក្ខុទាំងឡាយហើយ ។ មនុស្ស
ទាំងនោះក៏មានចិត្តរីករាយស្រស់ស្រាយឡើងថា យើងមុខជានឹងបានឲ្យ
ទាន មុខជានឹងបានធ្វើបុណ្យក្នុងកាលនេះឯង ចាប់ដើមតាំងពីព្រះដ៏មាន
ព្រះភាគទ្រង់បានអនុញ្ញាតគហបតិចីវរដល់ភិក្ខុទាំងឡាយ ។ ក្នុងក្រុងភគ
នេះមានចីវរច្រើនពាន់កើតឡើងតែក្នុង ១ ថ្ងៃប៉ុណ្ណោះ ។ ពួកមនុស្សដែល
នៅក្នុងជនបទបានឮដំណឹងថា គហបតិចីវរព្រះមានព្រះភាគទ្រង់បាន
អនុញ្ញាតដល់ភិក្ខុទាំងឡាយហើយ ។ មនុស្សទាំងនោះក៏មានចិត្តរីករាយ
ស្រស់ស្រាយឡើងថា យើងមុខជានឹងបានឲ្យទាន មុខជានឹងបានធ្វើ
បុណ្យក្នុងកាលនេះឯង ចាប់ដើមតាំងពីព្រះដ៏មានព្រះភាគទ្រង់បានអ-
នុញ្ញាតគហបតិចីវរដល់ភិក្ខុទាំងឡាយ ។ សូម្បីតែក្នុងជនបទក៏មានចីវរ
ច្រើនពាន់កើតឡើងតែក្នុង ១ ថ្ងៃប៉ុណ្ណោះ ។

(៤៣) សម័យនោះឯង សំពត់ចាវរ[1]កើតឡើងដល់សង្ឃ ។
ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ+ះបំពោះព្រះដ៏មានព្រះភាគ ។

---

១ សំពត់បែបយ៉ាងល្អដែលគេធ្វើមានលាយដោយភោមសត្វជាដើរ ។

អនុជានាមិ ភិក្ខវេ ចាតរន្តិ ។ តោសេយ្យថាបិភេ ចុល្លន្តោ ហោតិ ។ អនុជានាមិ ភិក្ខវេ តោសេយ្យថាបិភន្តិ ។ តោជវំ ចុល្លន្តំ ហោតិ ។ អនុជានាមិ ភិក្ខវេ តោជវន្តិ ។

បឋមភាណវារំ និដ្ឋិតំ ។

(៤៤) តេន ខោ បន សមយេន តាសីតជា ដីវកស្ស តោមារភច្ចស្ស អឌ្ឍតាសិយំ[1] តម្ពលំ ចាហោសិ ចុបឌ្ឍតាសីនំ ចុបអានំ[2] ។ អថខោ ដីវតោ តោមារភច្ចោ តំ អឌ្ឍតាសិយំ តម្ពលំ អាទាយ យេន ភគវា តេនុបសង្កមិ ចុបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯតមត្ថំ ឯរិសីនិ ។ ឯតមត្ថំ ឯរិសិន្តោ ខោ ដីវតោ តោមារភច្ចោ ភគវន្តំ ឯតទវោច អយំ មេ ភន្តេ អឌ្ឍតាសិយោ តម្ពលោ តាសីវញ្ចោ បហិតោ ចុបឌ្ឍតាសីនំ ចុបអានោ បដិក្ខឡ្ហាតុ មេ ភន្តេ ភគវា

• ម. អឌ្ឍកាសិកំ ។ ២ ឯមអានំ ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់ចាវរ ។ សំពត់ចាវរធ្វើពីសូត្រចានកើតឡើង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់ចាវរដែលគេធ្វើពីសូត្រ ។ សំពត់កោជវ:(១)ចានកើតឡើង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់កោជវ: ។

ចប់ ភាណវារ: ជាដំបូង ។

៤៤) សម័យនោះឯង ស្តេចកង្សវែនកាសី ចានបញ្ជូនសំពត់កម្ពលមានដំឡៃកន្ទុះពាន់(៩០០កហាបណ:)គឺប្រហែលនឹងវត្ថុទាំងឡាយដែលមានដំឡៃកន្ទុះពាន់ដែរ ទៅឲ្យដីវកកោមារកត្យ ។ លោះនោះ ដីវកកោមារកត្យក៏ចាននាំយកសំពត់កម្ពលមានដំឡៃកន្ទុះពាន់នោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ដីវកកោមារកត្យលុះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា សូមទ្រង់មេត្តាប្រោស សំពត់កម្ពលមានដំឡៃកន្ទុះពាន់របស់ខ្ញុំព្រះអង្គនេះ ប្រហែលនឹងវត្ថុទាំងឡាយដែលមានដំឡៃកន្ទុះពាន់ដែរ ស្តេចកាសីចានបញ្ជូនមកប្រទាន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ

---

១ (អដ្ឋកថាថា) សំពត់នេះប្រែប្រហែលគ្នានឹងសំពត់ចាវរ: សំពត់នេះគេធ្វើពីរោមសត្វ ។

កតញ្ញូសំ យំ មម អស្សូ ឧទ្ធរន្តំ មាតាយ សុខាយាតិ ។ បដិក្កមោសិ ភគវា តុណ្ហីភាវេន ។ អថខោ ភគវា ជីវកំ កោមារភច្ចំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ ជីវកោ កោមារភច្ចោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ តុណ្ហីភាវន្តិ ។

(៤៥) តេន ខោ បន សមយេន សង្ឃស្ស ឧច្ចាវចានិ ចីវរានិ ឧប្បជ្ជន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កីទិសំ នុ ខោ ភគវតា ចីវរំ អនុញ្ញាតំ កីវ អនេកញ្ញាតន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ

ទ្រង់ទទួលយកសំពត់កម្ពលរបស់ខ្ញុំព្រះអង្គ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គអស់កាលជាអង្វែង (តទៅ) ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលយកសំពត់កម្ពល ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ពន្យល់ដំរែកគោមារកត្ស ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ។ លំដាប់នោះ ដំរែកគោមារកត្សកាលដែលព្រះមានព្រះភាគទ្រង់ពន្យល់ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណហើយថយចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគក៏ទ្រង់ធ្វើធម្មីកថាក្នុងពេលនោះហើយ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទូរសំពត់កម្ពល ។

(៤៩) សម័យនោះឯង មានចីវរលួនធំមិនល្អ កើតឡើងដល់សង្ឃ ។ ភិក្ខុទាំងឡាយមានសេចក្តីរំពឹងគិតដូច្នេះថា ចីវរដូចម្តេចដែលព្រះមានព្រះភាគ ទ្រង់អនុញ្ញាតចីវរដូចម្តេច ដែលព្រះមានព្រះភាគមិនអនុញ្ញាត ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ បំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត

ភិក្ខវេ ឯ ចីវរានិ ខោមំ កប្បាសិកំ កោសេយ្យំ កម្ពលំ សាណំ ភង្គន្តិ ។ តេន ខោ បន សមយេន យេ តេ ភិក្ខូ គហបតិចីវរំ សាទិយន្តិ តេ កុក្កុច្ចាយន្តា បំសុ-ក្កូលំ ន សាទិយន្តិ ឯកំយេវ ភគវតោ ចីវរំ អនុញ្ញាតំ ន ទ្វេតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជា-នាមិ ភិក្ខវេ គហបតិចីវរំ សាទិយន្តេន បំសុក្កូលិកេន សាទិតុំ តទុភយេន ចាហំ ភិក្ខវេ សន្តុដ្ឋិំ វណ្ណេមីតិ ។

(៤៦) តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ កោសលេសុ ជនបទេសុ អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ ឯកច្ចេ ភិក្ខូ សុសានំ ពិក្ខាចរិំសុ បំសុក្កូលាយ ឯកច្ចេ ភិក្ខូ ឧច្ចរេសុំ ។ យេ តេ ភិក្ខូ សុសានំ ពិក្ខាចរិំសុ បំសុក្កូលាយ តេ បំសុក្កូលានិ លភិំសុ ។ យេ តេ ភិក្ខូ ឧច្ចរេសុំ តេ ឯវមាហំសុ អម្ហាកំបិ អាវុសោ

ចីវរ ៦ យ៉ាង គឺ ចីវរដែលធ្វើដោយសម្បកឈើ ១ ចីវរដែលធ្វើដោយកប្បាស ១ ចីវរដែលធ្វើដោយសូត្រ ១ ចីវរដែលធ្វើដោយកេមសត្ (រៀវលែងតែសក់ប្តកេមមនុស្សចេញ) ១ សំពត់ដែលធ្វើដោយសម្បកឈើ ១ សំពត់ដែលធ្វើលាយដោយវត្ថុ ៥ យ៉ាងខាងដើម ១ ។ សម័យនោះឯង ពួកភិក្ខុណាត្រេកអរនឹងគហបតិចីវរ ភិក្ខុទាំងនោះក៏រៀសមិនត្រេកអរនឹងសំពត់បង្សុកូលឡើយ ព្រោះគិតថា ព្រះដ៏មានព្រះភាគទ្រទ់អនុញ្ញាតតែចីវរ ១ មិនបានអនុញ្ញាតចីវរពីរទេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះបំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រទ់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលត្រេកអរនឹងគហបតិចីវរហើយ ត្រេកអរនឹងសំពត់បង្សុកូលផងក៏បាន ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត តថាគតសរសើរសេចក្តីសន្តោសដោយចីវរទាំងពីរយ៉ាងនោះ ។

(៤៦) សម័យនោះឯង មានភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយកងកោសលជនបទ ។ ភិក្ខុពួកខ្លះដើរទៅកាន់ព្រៃស្មសានដើម្បីនឹងបង្សុកូល ភិក្ខុពួកខ្លះមិនបានរង់ចាំឡើយ ។ ពួកភិក្ខុណាដើរទៅកាន់ព្រៃស្មសានដើម្បីនឹងបង្សុកូល ភិក្ខុទាំងនោះក៏បានសំពត់បង្សុកូលទាំងឡាយ ។ ពួកភិក្ខុណាដែលមិនបានរង់ចាំ ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែអាវុសោ

ភាគំ នេថាតិ ។ តេ ឣវមាហំសុ ន មយំ អាវុសោ
តុម្ហាកំ ភាគំ ទស្សាម តិស្ស តុម្ហេ ជានមិត្ថាតិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ តិក្ខវេ
ជានមេត្ថានំ ជានាមា ភាគំ ទាតុន្តិ ។ តេន ខោ បន
សមយេន សម្ពហុលា តិក្ខ្ហេ កោសលេសុ ជនបទេសុ
អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ ឯតទេ តិក្ខ្ហេ សុសានំ
ចិក្ខ្លមីសុ បំសុក្ខូលាយ ឯតទេ តិក្ខ្ហេ អាគមេសុំ ។
យេ តេ តិក្ខ្ហេ សុសានំ ចិក្ខ្លមីសុ បំសុក្ខូលាយ តេ
បំសុក្ខូលានំ លភីសុ ។ យេ តេ តិក្ខ្ហេ អាគមេសុំ
តេ ឣវមាហំសុ អម្ហាកំបិ អាវុសោ ភាគំ នេថាតិ ។ តេ
ឣវមាហំសុ ន មយំ អាវុសោ តុម្ហាកំ ភាគំ ទស្សាម
តិស្ស តុម្ហេ ន ចិក្ខ្លមិត្ថាតិ ។ ភគវតោ ឯតមត្ថំ អា-
រោចេសុំ ។ អនុជានាមិ តិក្ខវេ អាគមេត្ថានំ អភាគា
ភាគំ ទាតុន្តិ ។ តេន ខោ បន សមយេន សម្ពហុលា

ចូរលោកតាំងឆ្លាយឲ្យចំណែកមកយើងខ្ញុំ ។ កិក្ខុតាំងនោះក៏និយាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនឲ្យចំណែកដល់លោកតាំងឆ្លាយទេ (បើលោកតាំងឆ្លាយចង់ចាន់សំពត់បង្សុកូល) ហេតុដូចម្តេចបានជាលោកតាំងឆ្លាយមិនរង់ចាំយើង ។ កិក្ខុតាំងនោះគ្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុតាំងឆ្លាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមិនប្រាថ្នាធំឲ្យក៏កុំឲ្យនូវចំណែកដល់ភិក្ខុតាំងឆ្លាយដែលមិនរង់ចាំបាន ។ សម័យនោះឯង មានភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយកងកោសលជនបទ ។ ភិក្ខុពួកខ្លះដើរទៅកាន់ព្រៃស្មសានដើម្បីធំងបង្សុកូល ភិក្ខុពួកខ្លះបានរង់ចាំ ។ ពួកភិក្ខុណាចូលទៅកាន់ព្រៃស្មសានដើម្បីធំងបង្សុកូល ភិក្ខុតាំងនោះក៏បានសំពត់បង្សុកូល ។ ពួកភិក្ខុណាដែលរង់ចាំ ភិក្ខុតាំងនោះក៏និយាយយ៉ាងនេះថា នែអាវុសោ ចូរលោកតាំងឆ្លាយឲ្យចំណែកមកយើងខ្ញុំ ។ ភិក្ខុតាំងនោះពោលតបវិញយ៉ាងនេះថា នែអាវុសោ យើងមិនឲ្យចំណែកដល់លោកតាំងឆ្លាយទេ ហេតុម្តេចបានជាលោកតាំងឆ្លាយមិនចូលទៅ ។ ភិក្ខុតាំងនោះគ្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុតាំងឆ្លាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលទុកជាមិនបង់ឲ្យក៏ត្រូវឲ្យចំណែកដល់ភិក្ខុតាំងឆ្លាយដែលរង់ចាំ ។ សម័យនោះឯង មានពួកភិក្ខុច្រើនរូប

ภิกฺขู กาเมสุ ฉนฺทเทสุ อนฺธานมกฺขายิโน ฯ ฯเปฯ ภิกฺขู ปมานิ สุสานานิ ทิสฺวาปิ สุสานานิ ปสฺสิตฺวาปิ ฯ เอกจฺเจ

ដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងកោសលជនបទ ។ កិក្ខុពួកខ្លះ ដើរចូលទៅកាន់ព្រៃស្នួសានជាមុន ដើម្បីបង្សុកូល កិក្ខុពួកខ្លះដើរចូលទៅជាខាងក្រោយ ។ ពួកកិក្ខុណាដែលដើរចូលទៅព្រៃស្នួសានមុន ដើម្បីបង្សុកូល កិក្ខុទាំងនោះក៏បានសំពត់បង្សុកូល ។ ពួកកិក្ខុណាចូលទៅក្រោយ កិក្ខុទាំងនោះក៏គ្មានឡើយ ។ កិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែការុសោ លោកទាំងឡាយចូរឲ្យចំណែកដល់យើងខ្ញុំ ។ កិក្ខុទាំងនោះនិយាយយ៉ាងនេះវិញថា នែការុសោ យើងមិនបានឲ្យចំណែកដល់លោកទេ ហេតុអ្វីបានជាលោកទាំងឡាយដើរចូលទៅក្រោយគេ ។ កិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលកិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកិក្ខុដែលមិនចង់ឲ្យ ក៏កុំបាច់ឲ្យនូវចំណែកដល់កិក្ខុទាំងឡាយដែលដើរចូលទៅក្រោយគេ ។ សម័យនោះឯង មានពួកកិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងកោសលជនបទ ។ កិក្ខុទាំងនោះបានដើរចូលទៅកាន់ព្រៃស្នួសាន ដើម្បីបង្សុកូលត្រមគ្នា ។ កិក្ខុពួកខ្លះបានសំពត់បង្សុកូល កិក្ខុពួកខ្លះមិនបាន ។ ពួកកិក្ខុណាដែលមិនបាន កិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែការុសោ លោកទាំងឡាយចូរឲ្យចំណែកមកយើងខ្ញុំ ។ កិក្ខុទាំងនោះនិយាយយ៉ាងនេះវិញថា នែការុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ ហេតុអ្វីបានជា

สุมฺเห ฉ ลกฺขาสิ ฯ ภควาโต ฬหมตฺถ อาโรเจสุ ฯ อนุชานามิ ภิกฺขเว สงฺฆิสานิ ทฺวิกฺขตฺตุมตฺตานิ อคาเรน ภาสิ ตาตุนฺติ ฯ เตน โข ปน สมเยน สมฺพหุลา ภิกฺขู โกสลเสสุ ชนปเทสุ อทฺธานมคฺคปฺปฏิปนฺนา โหนฺติ ฯ เต ภตฺตกิจฺจ กตฺวา สุสานานิ ทฺวิกฺขตฺตุ ปริสุกฺขาย ฯ ฬหเตฺว ภิกฺขู ปริสุกฺขานิ ลภึสุ ฬหเตฺว ภิกฺขู ฉ ลภึสุ ฯ เย เต ภิกฺขู ฉ ลภึสุ เต ฬหมาหึสุ อมฺหากนฺติ อายุโส ภาสิ เชตาติ ฯ เต ฬหมาหึสุ ฉ มยนฺ อายุโส สุมฺหากนฺติ ภาสิ ฉสฺสุม ภิกฺขุ สุมฺเห ฉ ลภิตาติ ฯ ภควาโต ฬหมตฺถ อาโรเจสุ ฯ อนุชานามิ ภิกฺขเว ตาติสิ ตาตุนฺติ ทฺวิกฺขตฺตุมตฺตานิ อคาเรน ภาสิ ตาตุนฺติ ฯ

(๔๗) เตน โข ปน สมเยน มนุสฺสา ปิฬ อาหาย อารามิ อาคจฺฉนฺติ ฯ เต ปฏิคฺคาหกิ อลภมานา ปฏิหรนฺติ ฯ ปิฬ ปริกฺขยฺ ขุปฺปนฺติ ฯ ภควาโต

លោកមិនបានទទឹងគេ ។ កិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលទុកជាមិនចង់ឲ្យក៏ត្រូវឲ្យចំណែកដល់ភិក្ខុទាំងឡាយដែលចូលទៅកាន់ព្រៃស្មសានព្រមគ្នា ។ សម័យនោះឯង មានភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយក្នុងកោសលជនបទ ។ កិក្ខុទាំងនោះឃ្លានធ្វើកតិកា(ប្តេជ្ញា)ទទឹងគ្នារួចហើយ ក៏ចូលទៅកាន់ព្រៃស្មសានដើម្បីបង្អុំភ្លុះ ។ កិក្ខុពួកខ្លះបានសំពត់បង្អុំភ្លុះ កិក្ខុពួកខ្លះមិនបាន ។ ពួកកិក្ខុណាដែលមិនបាន កិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែអាវុសោ លោកទាំងឡាយចូរឲ្យចំណែកមកយើងខ្ញុំ ។ កិក្ខុទាំងនោះនិយាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ ហេតុអ្វីបានជាលោកមិនបានទទឹងគេ ។ កិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលទុកជាមិនចង់ឲ្យ ក៏ត្រូវឲ្យចំណែកដល់ភិក្ខុទាំងឡាយដែលធ្វើកតិកា(ប្តេជ្ញា)គ្នាហើយចូលទៅកាន់ព្រៃស្មសាន ។

(៤៧) សម័យនោះឯង ពួកមនុស្សបាននាំយកចីវរមកកាន់អាវាស ។ មនុស្សទាំងនោះកាលមិនបានកិក្ខុណាមួយទទួលចីវរ ក៏ត្រឡប់នាំយកចីវរទៅវិញ ។ ឯចីវរក៏កើតតិច ។ ទៅ ។ កិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ

ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គេ-
ហិ សមន្នាគតំ ភិក្ខុំ ចីវរប្បដិគ្គាហកំ សម្មន្និតុំ យោ
ន ឧត្តាគតិំ គច្ឆេយ្យ ន នោសាគតិំ គច្ឆេយ្យ ន មោ-
ហាគតិំ គច្ឆេយ្យ ន ភយាគតិំ គច្ឆេយ្យ កមាគាតមា-
គញ្ឆេ ជានេយ្យ ។ ឯវញ្ហេ បន ភិក្ខវេ សម្មន្និតព្ពោ ។
បឋមំ ភិក្ខុ យាចិតព្ពោ យាចិត្វា ព្យត្តេន ភិក្ខុនា
បដិពលេន សង្ឃោ ញាបេតព្ពោ សុណាតុ មេ ភន្តេ
សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ
ភិក្ខុំ ចីវរប្បដិគ្គាហកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។
សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ
ចីវរប្បដិគ្គាហកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ
ឥត្ថន្នាមស្ស ភិក្ខុនោ ចីវរប្បដិគ្គាហកស្ស សម្មុតិ សោ
តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ
សង្ឃេន ឥត្ថន្នាមោ ភិក្ខុ ចីវរប្បដិគ្គាហកោ ។ ខមតិ
សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

ចីវរក្ខន្ធក: ការសន្មតិកំពុងឲ្យជាអ្នកទទួលចីវរ

ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ៤ ឲ្យជាអ្នកទទួលចីវរ គឺ ភិក្ខុមិនបានលុះឆន្ទាគតិ ១ មិនបានលុះទោសាគតិ ១ មិនបានលុះមោហាគតិ១ មិនបានលុះភយាគតិ១ ដឹងនូវចីវរដែលខ្លួនបានទទួលនឹងមិនបានទទួល ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវសង្ឃសន្មតយ៉ាងនេះ ។ សង្ឃត្រូវអង្វរភិក្ខុជាមុន លុះអង្វរភិក្ខុហើយ ភិក្ខុដែលឆ្លាសប្រតិពលត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរចុះ ។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរ ។ ការសន្មតិភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរ គួរដល់លោកដ៏មានអាយុអង្គណាហើយ លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកទទួលចីវរហើយ ។ ការសន្មតិនេះសមគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការៈស្ងៀមនៅយ៉ាងនេះ ។

(๔๘) តេន ខោ បន សមយេន ចីវរប្បដិគ្គាហកា ភិក្ខូ ចីវរំ បដិគ្គហេត្វា តត្ថេវ ខុជ្ជិត្វា បក្កមន្តិ ។ ចី. វរំ ន សុដ្ឋតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជា. នាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ចីវរនិធា. ហកំ សម្មន្និតុំ យោ ន ឆន្ទាគតិំ គច្ឆេយ្យ ន ទោ. សាគតិំ គច្ឆេយ្យ ន មោហាគតិំ គច្ឆេយ្យ ន ភយាគតិំ គច្ឆេយ្យ ន ទិដ្ឋធម្មនិទ្ធានិតញ្ច[1] ជានេយ្យ ។ ឥមេហិ ខោ ភិក្ខវេ សមន្នាគតោ ។ បឋមំ ភិក្ខុ យាចិតព្ពោ យាចិត្វា ញត្តិយា ភិក្ខូនំ បដិពលេន សង្ឃេន ញា. បេតព្ពោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ចីវរនិធាហកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ចីវរនិធាហកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ចីវរនិ. ធាហកស្ស សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ

---

๑ ម. និហិតានិហិតញ្ច ។

(៤៨) សម័យនោះឯង ពួកភិក្ខុអកទទួលចីវរ ឲ្យនទទួលចីវរទុក ចោលក្នុងពីនោះឯង ហើយចៀសចេញទៅ ។ ចីវរក៏រិនាសទៅ ។ ភិក្ខុ ទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុ ដែលប្រកបដោយអង្គ៥ ឲ្យជាអ្នកទុកជាក់ចីវរ គឺភិក្ខុដែលមិនលុះឆន្ទាគតិ១ មិនលុះទោសាគតិ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ដឹងនូវចីវរ ដែលខ្លួនបានទុកជាក់ហើយនឹងមិនទាន់បានទុកជាក់ហើយ ១ ។ ម្នាលភិក្ខុ ទាំងឡាយ ត្រូវសង្ឃសន្មតយ៉ាងនេះ ត្រូវសង្ឃអង្វរភិក្ខុជាមុន លុះ អង្វរហើយ ភិក្ខុអកធ្វាសប្រតិពលត្រូវញ៉ាំងសង្ឃឲ្យដឹងថា បពិត្រ ព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់ សង្ឃហើយ គួរសង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទុកជាក់ចីវរ ។ នេះជា ពាក្យផ្តែងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទុកជាក់ចីវរ ។ ការសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទុកជាក់ចីវរសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មាន អាយុអង្គនោះត្រូវស្ងៀម(បើ)មិនសមគួរដល់លោកដ៏មានអាយុអង្គណាទេ

เสา ภาเสยฺย ฯ สมฺมโต สงฺเฆน ปตฺตคฺคาหโก ภิกฺขุ ปีวาธิปาหาโรติ ฯ เอวญฺหิ สงฺฆสฺส ปุญฺญา ฯ เอวเมตํ ธารยามีติ ฯ

(๔๙) เตน เขา ปน สมเยน ปีวาธิปาหารา ภิกฺขู มญฺจาปีเปปิ ปุจฺฉนฺตาปิ อิงฺฆาติ. เสปิ ปีฐํ อิงฆนฺติ ฯ จุณฺหเปปิ จุปจิกาหิปิ เขฑฺฑนฺติ ฯ ภควาโต เอตมตฺถํ อาโรเจสุ ฯ อนุชานามิ ภิกฺขเว ภณฺฑาคารํ สมฺมนฺนิตุ์ ยํ สงฺฆา อากงฺขติ วิหารํ วา อฑฺฒโยคํ วา ปาสาทํ วา หมฺมิยํ วา ปุถุ์ วา ฯ เอวญฺจ ปน ภิกฺขเว สมฺมนฺนิตพฺโพ ฯ ญตฺติสมฺปนฺเน ภิกฺขุนา ปติรูเปน สงฺฆา ญาเปตพฺโพ สุณาตุ เม ภนฺเต สงฺฆา ยทิ สงฺฆสฺส ปตฺตกลฺลํ สงฺฆา เอตฺถาหิ วิหารํ ภณฺฑาคารํ สมฺมนฺเนยฺย ฯ เอสา ญตฺติ ฯ สุณาตุ เม ภนฺเต สงฺฆา สงฺฆา เอตฺถาหิ วิหารํ ภณฺฑาคารํ สมฺมนฺ-ติ ฯ ยสฺสายสฺมโต ขมติ เอตฺถาหิ วิหารสฺส

លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ កិក្ខុឈ្មោះនេះសង្ឃបាន
សន្មតឲ្យជាអ្នកទុកដាក់ចីវរហើយ ។ ការសន្មតនេះសមគួរដល់សង្ឃ
ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយ
អាការស្ងៀមនៅយ៉ាងនេះ ។

(៤៩) សម័យនោះឯង ពួកភិក្ខុអ្នកទុកដាក់ចីវរ ទុកចីវរក្នុង
មណ្ឌប (ឃ្លាំង) ខ្លះ ក្រោមម្លប់ឈើខ្លះ ទៀបយុះស្បៃខ្លះ ក្នុងទីកណ្តាល
វាលខ្លះ ។ ពួកសត្វកណ្តុរខ្លះ ពួកសត្វកណ្តៀរខ្លះ ក៏កាត់ចីវរទាំងនោះ ។
កិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គ
ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ (បើ) សង្ឃប្រាថ្នានូវណា គឺ
វិហារក្តី ប្រាសាទមានសណ្ឋានដូចស្មាបគ្រឿងក្តី ប្រាសាទវែងក្តី
ប្រាសាទមានជំបូលត្រងិលក្តី គូហាក្តី ក៏តថាគតអនុញ្ញាតឲ្យសង្ឃសន្មត
នូវនោះឲ្យជាឃ្លាំងបាន ។ ម្នាលភិក្ខុទាំងឡាយ គួរសង្ឃសន្មតយ៉ាង
នេះ ។ ត្រូវភិក្ខុអ្នកឆ្លាសប្រតិពលញ្ញាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃ
ដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ
សង្ឃគួរសន្មតវិហារឈ្មោះនេះ ឲ្យជាឃ្លាំងបាន ។ នេះជាពាក្យផ្តើម
សង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃ
សន្មតវិហារឈ្មោះនេះ ឲ្យជាឃ្លាំងហើយ ។ ការសន្មតវិហារឈ្មោះនេះ

កល្លាតារស្ស សង្ឃតិ សោ តុណ្ហាស្ស យស្ស ឧក្ខ-
មតិ សោ អាសេយ្យ ។ សម្មុតា សង្ឃេន ឥត្ថន្នាមោ
វិហារេ កល្លាតារំ ។ ឯមតិ សង្ឃស្ស តស្មា តុណ្ហី ។
ឯវមេតំ ធារយាមីតិ ។

(៤០) តេន ខោ បន សមយេន សង្ឃស្ស កល្លា-
តារេ ចីវរំ អកុត្តំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេ-
សុំ ។ អនុជានាមិ ភិក្ខវេ បញ្ចមាឡេមិ សមណ្ឌលំ
ភិក្ខុំ កល្លាតារិតំ សម្មន្និតុំ យោ ន ឆន្នាគតិ តច្ឆេយ្យ
ន នោសាគតិ តច្ឆេយ្យ ន មោហាគតិ តច្ឆេយ្យ ន ភ-
យាគតិ តច្ឆេយ្យ កុត្តាកុត្តញ្ច ជានេយ្យ ។ ឯវញ្ច បន
ភិក្ខវេ សម្មន្និតព្ពោ ។ បឋមំ ភិក្ខុ យាចិតព្ពោ យាចិត្វា
ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្ពោ
សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ
សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ កល្លាតារិតំ សម្មន្នេយ្យ ។

ឲ្យជាឃ្លាំង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម(ប៉ៈ)មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ វិហារឈ្មោះនេះសង្ឃបានសន្មតឲ្យជាឃ្លាំងហើយ ។ ការសន្មតិគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

(៥០) សម័យនោះឯង ចីវរក្នុងឃ្លាំងរបស់សង្ឃឥតមានលោកណា គ្រប់គ្រងរក្សាឡើយ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នករក្សាឃ្លាំង គឺភិក្ខុដែលមិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ដឹងនូវរបស់ដែលខ្លួនបានគ្រប់គ្រងរក្សាហើយនឹងមិនភាន់ភ្លេចគ្រប់គ្រងរក្សា ១ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ ។ សង្ឃត្រូវអង្វរកភិក្ខុជាមុន លុះអង្វរករហើយ ភិក្ខុអកត្ថាសប្រតិពលត្រូវញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគួរសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នករក្សាឃ្លាំង ។

ฌานา ญาตุ ฯ สุขาภาวา เย เกจิ สเตฺตสุ สเตฺตสุ
สัตตาธิปัญญัตติ กิญจิ กสิณภาคาทิกัง สมาปัชชติ ฯ ยสฺสายสฺมา-
โต อิมสฺมิ สัตตาธิปัญญัตติสฺมิ กิญจิกสิณภาคาทิกสฺส
สมาปัตติสฺส สมาปัชชนาสฺส ยสฺส อนาวัชชิตสฺมิ สมา-
ปัตติยา ฯ สมาปัตติยา สเตฺตสุ สัตตาธิปัญญัตติยา กิญจิ กสิณภา-
คาทิกา ฯ อิมสฺมิ สมาปัชชนาสฺส ตสฺมา สุขาภา ฯ ฌานาทีสุ
ฌานาทิกา ฯ

[๕๑] เตน โข ปน สมเยน อญญตโร ภิกขุ กิญจิ
กสิณภาคาทิกัง ปาปุณาติ ฯ ภควาโต ฌานาทีสุ อาภาเต-
สุ ฯ อ กิญจิกสิณ กสิณภาคาทิกา ปาปุณาติ ยา ปาปุณาติ อาทีสุ ทุกกฏสฺสาติ ฯ

ជំរកទួក: ការសន្មតភិក្ខុឲ្យជាអ្នករក្សាឃ្លាំង

នេះជាពាក្យផ្តឿនសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នករក្សាឃ្លាំង ។ ការសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នករក្សាឃ្លាំង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នករក្សាឃ្លាំងហើយ ។ ការសន្មតិនេះគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

(៥១) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបណ្តេញភិក្ខុអ្នករក្សាឃ្លាំងឲ្យចៀសចេញ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបណ្តេញ[1] ភិក្ខុអ្នករក្សាឃ្លាំងចេញទេ ភិក្ខុណាបណ្តេញ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

---

១ បុគ្គលដែលមិនត្រូវបណ្តេញចេញចាកទីកន្លែងមាន ៤ ពួក គឺភិក្ខុថាស់ដាង ១ ភិក្ខុជាអ្នករក្សាឃ្លាំង ១ ភិក្ខុមានដំបូង ១ ភិក្ខុដែលបានសេនាសនៈអំពីសង្ឃ ១ ។ ភិក្ខុក្មេងមិនត្រូវបណ្តេញភិក្ខុថាស់ចេញ ព្រោះលោកថាស់ដាងខ្លួន ។ ភិក្ខុជាអ្នករក្សាឃ្លាំង ភិក្ខុមិនត្រូវបណ្តេញចេញ ព្រោះសង្ឃបានសន្មតឲ្យជាអ្នករក្សាឃ្លាំង ។ ភិក្ខុមានដំបូង ភិក្ខុមិនត្រូវបណ្តេញចេញ ព្រោះលោកឈឺ ។ ភិក្ខុដែលបានសេនាសនៈអំពីសង្ឃ ភិក្ខុមិនត្រូវបណ្តេញចេញ ព្រោះសង្ឃបានឲ្យទីកន្លែងជាទីសម្រាយដល់លោកដែលដាំពហូសូត្រ មានឧបការៈដល់សង្ឃដោយកិច្ចមានបង្រៀនជាដើម (អដ្ឋកថា) ។

(๙๒) เตน โข ปน สมเยน สงฺฆสฺส กณฺฑา-
กาเร ปีฐํ ทุสฺสนฺถตํ โหติ ฯ ภควาปิ ตตฺถ นิสีทิตุกาโม
สิ ฯ อถ ชานามิ ภิกฺขเว สมฺพหุลา เตน สงฺฆสฺส ปา-
ปิจฺฉตฺตนฺติ ฯ เตน โข ปน สมเยน สงฺฆา สงฺฆสฺส
ปีฐํ ปาปเณฺฑ เปาลมฺพมาลมฺพ อปฺปาสิ ฯ ภควาปิ นิส-
ทิตุกาโม อโหสิ ฯ อถ ชานามิ ภิกฺขเว ปญฺหาเมฺปหิ
สมฺปฺปาปตฺตึ ภิกฺขุ ปีฐปาปณฺณ สมฺปฺปฏิจฺฉิตุ์ โย น ปฏิ-
ปตฺติ ปฏิปฺปสฺสทฺธิ น ปาโมชฺชปฺปตฺติ ปฏิปฺปสฺสทฺธิ น ปามุชฺชปฺปตฺติ
ปฏิปฺปสฺสทฺธิ น ปยาปตฺติ ปฏิปฺปสฺสทฺธิ ปาฏิปาปฏิปฺปสฺสทฺธิ ปา-
เนยฺย ฯ ปญฺหา ปน ภิกฺขเว สมฺปฺปฏิปฺปสฺสทฺธิปฺหา ฯ ปปมํ
ภิกฺขุ ยาปิปฺหา ยาปิปฺหา ปฺยาปฺปเน ภิกฺขุปา ปฏิปฺปสฺสทฺธิ
สงฺฆสฺส ปาปฺหา ปฺยาปตฺตึ สุณาตุ เม ปาเนฺต สงฺฆสฺส ยทิ
สงฺฆสฺส ปตฺตปาลฺ สงฺฆสฺส ปฺปฏิปฺปสฺสทฺธิ ภิกฺขุ ปีฐปาปณฺณ
สมฺปฺปเนฺยยฺย ฯ เอสา ญตฺติ ฯ สุณาตุ เม ปาเนฺต

(៥២) សម័យនោះឯង ចីវរកម្មរបស់សង្ឃកំសម្បូណ៌ឡើង ។ កិកុខាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលកិកុខាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃដែលនៅជួបជុំគ្នា[1]ចែកចីវរបាន ។ គ្រានោះឯង សង្ឃខាំងពួងកាលចែកចីវរក៏បានធ្វើនូវសេចក្តីកោលាហលឡើង ។ កិកុខាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលកិកុខាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតកិកុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកចែកចីវរបាន គឺ កិកុដែលមិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះកយាគតិ ១ ដឹងនូវបរិស៊ដែលខ្លួនបានចែកហើយ និងមិនទាន់បានចែក ១ ។ ម្នាលកិកុខាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ ។ សង្ឃត្រូវអង្វរកកិកុជាមុន លុះអង្វរករួចហើយ កិកុអកធ្វាសប្រតិពលត្រូវញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគួរសន្មតកិកុឈ្មោះនេះឲ្យជាអ្នកចែកចីវរ ។ នេះជាពាក្យផ្តឿងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ

---

១ បានដល់សង្ឃដែលនៅខាងក្នុងនៃបរិវាសីមាជាមួយគ្នា (អដ្ឋកថា) ។

สเงฺฆ สเงฺฆ ฯ ตฺตญฺญตมํ ภิกฺขุ ปีวิภงฺคสมฺมตี ฯ
ยสฺมายสฺมเตา ๑ ตมติ ฯ ตฺตญฺญตมสฺส ภิกฺขุโต ปีวิภงฺ-
กสฺส สมฺมติ เสา ตุณฺหีภาสฺส ยสฺส ขมฺมติ เสา
ภาเสยฺย ฯ สมฺมเตา สเงฺฆน ฯ ตฺตญฺญาเมา ภิกฺขุ ปีวิ-
ภงฺคาติเตา ฯ ๑ ตมติ สเงฺฆสฺส ตสฺมา ตุณฺหี ฯ ยาเมตํ
ธารยามีติ ฯ อยเมา ปีวิภงฺคาติเตา ภิกฺขุโต ปาต-
เมาสิ กรเต ขุ เมา ปีวิ ภาเสตพฺพนฺติ ฯ ภควเตา ปา-
มตฺตํ อาโรเจสุ ฯ อยุปาลาติ ภิกฺขเว ปมมิ ทุปฺปิลิตฺตา
ตุลยิตฺวา วณฺณาวณฺณิ กตฺวา ภิกฺขุ กเลตฺวา วตฺตุ ทปฺปิตฺวา
ปีวิปฺปฏิวิสิ ปาเตตพฺพนฺติ ฯ อยเมา ปีวิภงฺคาติเตา ภิกฺขุโต
ปาตเมาสิ กรเต ขุ เมา สาเมเลาภาติ ปีวิปฺปฏิวิเสา
ชาตเพฺยาติ ฯ ภควเตา ปาตเมตฺตํ อาโรเจสุ ฯ อยุ-
ปาลาติ ภิกฺขเว สาเมเลาภาติ ทุปฺปิลิตฺตา ชาตุนฺติ ฯ

ចីវរក្ខន្ធកៈ ការសន្មតភិក្ខុឲ្យជាអ្នកចែកចីវរ

សង្ឃសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកចែកចីវរ ។ ការសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកចែកចីវរគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គ នោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មាន អាយុអង្គនោះគប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះសង្ឃបានសន្មតឲ្យជា អ្នកចែកចីវរហើយ ។ ការសន្មតិនេះគួរដល់សង្ឃហើយ ព្រោះហេតុ នោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអា-ការស្ងៀមនៅយ៉ាងនេះ ។ លំដាប់នោះ ពួកភិក្ខុអ្នកចែកចីវរ មានសេចក្តី រិះគិតដូច្នេះថា យើងគួរចែកចីវរដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំ ទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជ្រើសរើស (ចីវរ) ជាមុន ហើយសួរមើល (ដង្វែង) ហើយលែលកចីវរដែលមានសណ្ឋានតូចធំថ្លឹង ច្រឹនតិច (ឲ្យមានចំណែកស្មើគ្នា) ហើយកាប់កិត្តិ ហើយចងចីវរឲ្យជា ពួក ៗ រួច សឹមដំកល់ទុកនូវចំណែកនៃចីវរ ។ លំដាប់នោះ ពួកភិក្ខុអ្នក ចែកចីវរមានសេចក្តីរិះគិតដូច្នេះថា យើងត្រូវឲ្យចំណែកចីវរដល់ពួកសាម-ណេរដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏-មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុទាំងឡាយឲ្យចំណែកពាក់កណ្តាលដល់ពួកសាមណេរ ។

តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សតេន
ការេន ទុត្តរិតុការោ ហោតិ ។ ភគវតោ ឯតមត្ថំ អា-
រោចេសុំ ។ អនុជានាមិ ភិក្ខវេ ទុត្តរន្តស្ស សតំ ភាតុំ
ធាតុន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ
អតិរេកការេន ទុត្តរិតុការោ ហោតិ ។ ភគវតោ ឯត-
មត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អនុក្កមេ ឋិន្តេ
អតិរេកភាតុំ ធាតុន្តិ ។ អថខោ ចីវរភាជកានំ ភិក្ខូនំ
ឯតទហោសិ កថំ នុ ខោ ចីវរប្បដិវីសោ ធាតព្ពោ
អាគតប្បដិបាដិយា នុ ខោ ទុជាហុ យថាវុឌ្ឍន្តិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ
វិការេ តោសេត្វា ភុសថាតំ ការេតុន្តិ ។

(៩៣) តេន ខោ បន សមយេន ភិក្ខូ ឧភតោ-
ឧបិ បណ្ឌុមត្តិការេបិ ចីវរំ រជន្តិ ។ ចីវរំ ទុព្ពណ្ណំ

សម័យនោះឯង ភិក្ខុ១រូបមានសេចក្តីប្រាថ្នានឹងឆ្លងស្នឹងឬឆ្លងផុតទៅហើយ បានចំណែករបស់ខ្លួន (ជាប់ទៅផង) ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យចំណែករបស់ខ្លួន (គឺរបស់ភិក្ខុអ្នកឆ្លងស្នឹង) ដល់ភិក្ខុអ្នកឆ្លង (ស្នឹងឬផុតទៅហើយ) ចុះ ។ សម័យនោះឯង ភិក្ខុ១រូបមានសេចក្តីប្រាថ្នានឹងឆ្លងស្នឹងឬឆ្លងផុតទៅហើយបានចំណែកថ្លៃច្រើនជាងគេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើកប្បិយកណ្ឌគេបានឲ្យហើយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យចំណែកដ៏ច្រើនចុះ ។ គ្រានោះ ពួកភិក្ខុអកចែកចីវរ មានសេចក្តីនឹកគិតដូច្នេះថា យើងត្រូវឲ្យចំណែកចីវរដូចម្តេចហ្ន៎ យើងត្រូវឲ្យចំណែកចីវរដោយលំដាប់ភិក្ខុដែលមកឬ ។ ឬងត្រូវឲ្យចំណែកចីវរតាមលំដាប់ភិក្ខុចាស់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើចីវរខ្វះហើយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយញុាំងភិក្ខុឲ្យត្រេកអរសិន ហើយសឹមធ្វើការចុះស្លាក ។

(៥៣) សម័យនោះឯង ភិក្ខុទាំងឡាយដែលក់ចីវរដោយអាចម៍គោខ្លះ ដោយដីស្អិតមានពណ៌លឿងខ្លះ ។ ចីវរនោះក៏មានពណ៌មិនល្អ ។

เหาติ ฯ ภควาเต ปาตพฺยตาย อาโรเจสุ ฯ อนุชานามิ ภิกฺขเว ฉ วสฺสานิ ปมวสฺสกาลํ ทุติยวสฺสกาลํ ตติยวสฺสกาลํ จตุตฺถวสฺสกาลํ ปญฺจมวสฺสกาลนฺติ ฯ เตน โข ปน สมเยน ภิกฺขู สีตูทกายา[๑]ปีวาเรนฺติ ฯ ปีวา ทุกฺกฏนฺติ เหาติ ฯ ภควาเต ปาตพฺยตาย อาโรเจสุ ฯ อนุชานามิ ภิกฺขเว วสฺสานิ ปจิตุ ปจฺฉาวสฺสากาลมฺปิ ฯ วสฺสานิ ทุสฺสา-ยติ ฯ ภควาเต ปาตพฺยตาย อาโรเจสุ ฯ อนุชานามิ ภิกฺขเว อุตฺตภงฺคา[๒]ตฺวาปิตุนฺติ ฯ เตน โข ปน สมเยน ภิกฺขู น ชานนฺติ วสฺสานิ ปวิฏฺโ วา อปวิฏฺโ วา ฯ ภควาเต ปาตพฺยตาย อาโรเจสุ ฯ อนุชานามิ ภิกฺขเว อุทเก

---

๑ ฉ สีตูทกาย ฯ ๒ ฉ. อตฺตภงฺคา ฯ

កិកុខាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកុខាំងឡាយ តថាគតអនុញ្ញាតទឹកជ្រលក់ ៦ យ៉ាង គឺ ទឹកជ្រលក់កើតពីមើម ១ ទឹកជ្រលក់កើតពីដើម ១ ទឹកជ្រលក់កើតពីសម្បក ១ ទឹកជ្រលក់កើតពីស្នឹក ១ ទឹកជ្រលក់កើតពីផ្កា ១ ទឹកជ្រលក់កើតពីផ្លែ ១ ។ សម័យនោះឯង កិកុខាំងឡាយជ្រលក់ចីវរដោយទឹកត្រជាក់ ។ ចីវរនោះក៏មានក្លិនមិនល្អ ។ កិកុខាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកុខាំងឡាយ តថាគតអនុញ្ញាតឲ្យដាំងជ្រលក់តូច ដើម្បីដាំទឹកជ្រលក់ ។ ទឹកជ្រលក់ក៏ផុសឡើង ។ កិកុខាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកុខាំងឡាយ តថាគតអនុញ្ញាតឲ្យចងបៃតាស[1] ។ សម័យនោះឯង កិកុខាំងឡាយមិនដឹងទឹកជ្រលក់ឆ្អិនហើយឬនៅមិនទាន់ឆ្អិន ។ កិកុខាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកុខាំងឡាយ តថាគតអនុញ្ញាតឲ្យបន្តក់[2]ដំណក់ទឹក

---

១ គឺដាក់ឈើតាវាងនៅមាត់ឆ្នាំង ដើម្បីកុំឲ្យត្រឿងជ្រលក់មានចំណាំងឈើជាដើមផុលឡើងបាន ។ ២ បើទឹកជ្រលដាំពុសហើយយកទៅបន្តក់លើភាជនៈទឹក (ជីវ៍) ក៏មិនសាយចេញរហ័ស ឬបន្តក់លើខ្នងក្របកក៏ផ្ទុះពងែរ (អដ្ឋកថា) ។

ग्ग ङ१पिट्ठिकाय ग्ग ठेरकं ङात्वन्तं ॥ तेन खो पन समयेन कित्ति रञ्ञो पिवेय्यका कुम्भी आरद्धन्ति कुम्भी किट्ठति ॥ ककचेन पटिमन्तं आचेतेसुं ॥ अनुजानामि किन्तरे रञ्ञन्तेपुरं ङण्हकथालिकन्ति ॥ तेन खो पन समयेन किन्तिं रञ्ञकाङं ङ सिंवेत्ति ॥ ककचेन पटिमन्तं आचेतेसुं ॥ अनुजानामि किन्तरे रञ्ञनोकासं रञ्ञयङन्ति ॥ तेन खो पन समयेङ ङ किन्ति चातियापि पत्तेपि चीरं मङ्गन्ति[1] ॥ चीरं पारिकिट्ठति ॥ ककचेन पटिमन्तं आचेतेसुं ॥ अनुजानामि किन्तरे रञ्ञनोकासिकन्ति ॥ तेन खो पन समयेन किन्ति ङमायं चीरं पत्तरन्ति चीरं पंसुकितं होति ॥ ककचेन पटिमन्तं आचेतेसुं ॥ अनुजानामि किन्तरे तिणासन्थारकन्ति ॥ तिणासन्थारके चुपचिकाहि खज्जति ॥ ककचेन पटिमन्तं आचेतेसुं ॥ अनुजानामि किन्तरे

---

१ ङ. सम्मुखन्ति ॥

លើទឹកក៏បាន លើខ្នងក្រចកក៏បាន ។ សម័យនោះឯង កិកូតាំងឡាយកាល
ដាក់ទឹកជ្រលក់ក៏ទង្គិចនឹងធ្នាំង ។ ក៏បែកទៅ ។ កិកូតាំងនោះក្រាបបង្គំទូល
សេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកូ
តាំងឡាយ តថាគតអនុញ្ញាតនូវចោយសម្រាប់ដងទឹកជ្រលក់ដែលមាន
ដង ។ សម័យនោះឯង ភាជនសម្រាប់ដាក់ទឹកជ្រលក់របស់កិកូតាំងឡាយ
មិនទាន់មាន ។ កិកូតាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះ
ភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលកិកូតាំងឡាយ តថាគតអនុញ្ញាតនូវ
ធ្នាំងសម្រាប់ដាក់ទឹកជ្រលក់នឹងភ្ជុមសម្រាប់ដាក់ទឹកជ្រលក់ ។ សម័យ
នោះឯង កិកូតាំងឡាយគក់ចីវរកន្ធថាសខ្លះកន្ធថាត្រខ្លះ ។ ចីវរក៏ដាច់ដាច
អស់ ។ កិកូតាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។
ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកូតាំងឡាយ តថាគតអនុញ្ញាតនូវស្នូក
សម្រាប់ជ្រលក់ ។ សម័យនោះឯង កិកូតាំងឡាយត្រដាងហាលចីវរលើ
ផែនដី ចីវរក៏ប្រឡាក់ដោយអាចម៍ដី ។ កិកូតាំងនោះក្រាបបង្គំទូលសេចក្តី
នុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកូ
តាំងឡាយ តថាគតអនុញ្ញាតនូវកម្រាលស្មៅ ។ កម្រាលស្មៅពួកសត្វ
កណ្តៀរកោរអស់ទៅ ។ កិកូតាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះ
ព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកូតាំងឡាយ

ជីវកំ ជីវកត្ថុន្តិ ។ មជ្ឈេន លេក្ខន្តិ វដេ ខុភតោ
កលតំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជា-
នាមិ ភិក្ខវេ កណ្ណោ ពន្ធិតុន្តិ ។ កណ្ណោ ជីវតំ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ
កណ្ណសុត្តកន្តិ ។ វដេ ឯកតោ កលតំ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សម្បរិវត្តកំ
សម្បរិវត្តកំ វដេតុំ ន ច អញ្ញេន ថេវ បក្កមិតុន្តិ ។
តេន ខោ បន សមយេន ជីវកំ បត្តិន្តុំ ហោតិ ។ ភគ-
វតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ទុនតេ
ទិសាតេតុន្តិ ។ តេន ខោ បន សមយេន ជីវកំ ជរុសំ
ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជា-
នាមិ ភិក្ខវេ ចាណិនា អាសោដេតុន្តិ ។

ចីវរក្ខន្ធក: ការទ្រទ្រង់អនុញ្ញាតខ្សែសម្រាប់ចងដាយចីវរដោយដើម

តថាគតអនុញ្ញាតនូវឈើស្នាសម្រាប់ហាលចីវរនឹងខ្សែស្បៃង ។ កិក្ខុទាំង
ឡាយពាក់ចីវរចំពីពាក់កណ្តាល ទឹកជ្រលក់ក៏ហៀរចុះទៅតាមជាយទាំង
ពីរ ។ កិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។
ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចង
ត្រង់ជាយចីវរ ។ ជាយចីវរក៏ទក់ ។ កិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តី
នុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង
ឡាយ តថាគតអនុញ្ញាតនូវខ្សែសម្រាប់ចងជាយចីវរ ។ ទឹកជ្រលក់ក៏ហៀរ
ទៅតាមជាយម្ខាង ។ កិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មាន
ព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត
ឲ្យជ្រលក់ចីវរក្រែតឲ្យចប់ឲ្យសព្វគ្រប់ ម្យ៉ាងទៀត កាលបើដំណក់ទឹកមិន
ទាន់ជាប់អស់ទេ កិក្ខុកុំអាលដើរចេញឡើយ ។ សម័យនោះឯង ចីវរដិត
ខ្ចាំងពេក ។ កិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះ
ភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យត្រាំ
ចីវរទៅក្តង់ទឹក (ទេ) ។ សម័យនោះឯង ចីវរក៏មានសាច់រឹង ។ កិក្ខុទាំង
ឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់
ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគក់ចីវរដោយដៃ ។

(៥៤) តេន ខោ បន សមយេន ឆព្ភិក្ខិយា កិក្ខូ អច្ឆិន្នកានិ ចីវរានិ ជាវេន្តិ ទន្តកសាវានិ ជាវេន្តិ ។ មក្កុសច្ឆា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ(១) ។ កិក្ខូ(២) ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន កិក្ខវេ អច្ឆិន្នកានិ ចីវរានិ ជាវេតព្ពានិ យោ ជាវេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៥៥) អថខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា យេន ឧក្កិណាភិរិ តេន ចារិកំ បក្កាមិ ។ អទ្ទសា ខោ ភគវា មាគធកេ ភេត្តំ(៣) អច្ចិពទ្ធំ ចាលិពទ្ធំ មរិ-យាទពទ្ធំ សិង្ឃាដកពទ្ធំ(៤) ឯិស្សាន អាយស្មន្តំ អានន្ទំ អាមន្តេសិ បស្សសិ ខោ ត្វំ អានន្ទ មាគធកេ ភេត្តំ អច្ចិពទ្ធំ ចាលិពទ្ធំ មរិយាទពទ្ធំ សិង្ឃាដកពទ្ធន្តិ ។

---

១ ឥទំ បរំ ឧភោបិ យោគេសុ ទិស្សតិ ។ ២ តត្ថាយំ បាឋោ ឧ ហោតិ ។ ៣ ឧ. មគធកេ ភេត្តំ ។ ៤ អច្ចិពទ្ធំ ចាលិពទ្ធំ មរិយាទពទ្ធំ សិង្ឃាដិពពទ្ធំ ។

(๕๒) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ចីវរមិនបានកាត់ ទ្រទ្រង់ចីវរដែលកត់ដោយទឹកចត់មានពណ៌ដូចក្អុក ។ មនុស្សទាំងឡាយក៏បោលទោស តិះដៀល បន្ទុះបង្អាប់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនត្រូវប្រើប្រាស់ចីវរដែលមិនបានកាត់ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

(๕๓) គ្រានោះ ព្រះមានព្រះភាគគង់នៅក្នុងក្រុងភគ្គឹនះដោយសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយក៏ទ្រង់យាងចេញទៅ កាន់ចារិកក្នុងខុតិណាគិរីដែនបទ ។ ព្រះមានព្រះភាគទ្រង់ឃើញស្រែអ្នកដែនមគធៈមានសណ្ឋានជាស្រែមានជ្រុងបួន មានសណ្ឋានជាស្រែមានភ្ជួរវែងដោយបណ្តោយផងទទឹងផង មានសណ្ឋានជាស្រែមានភ្ជួរខ្វឹកក្នុងចន្លោះ ។ មានសណ្ឋានជាបួនជ្រុងដោយមានភ្ជួរខ្វឹចាញ់គ្នា លុះទ្រង់ទតឃើញហើយក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា នែអានន្ទ អ្នកឃើញស្រែអ្នកដែនមគធៈ មានសណ្ឋានជាស្រែមានជ្រុងបួន មានសណ្ឋានជាស្រែមានភ្ជួរវែងដោយបណ្តោយផងទទឹងផង មានសណ្ឋានជាស្រែមានភ្ជួរខ្វឹកក្នុងចន្លោះ ។ មានសណ្ឋានជាបួនជ្រុងដោយមានភ្ជួរខ្វឹចាញ់គ្នាឬទេ ។

ឯវំ ភគ្គេតិ ។ ឧស្សហាមិ ភន្តេ អានន្ទ កិក្ខូនំ ឯវរូបានិ ចីវរានិ សំវិទហិតុន្តិ ។ ឧស្សុបកាមិ ភគវាតិ ។ អថខោ ភគវា ធម្មិំណាតិវស្មឹ យថាភិរន្តំ វិហរិត្វា បុនទេវ រាជគហំ បច្ចាគច្ឆិ ។ អថខោ អាយស្មា អានន្ទោ សម្ពហុលានំ កិក្ខូនំ ចីវរានិ សំវិទហិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច បស្សតុ[1] មេ ភន្តេ ភគវា ចីវរានិ សំវិទ-ហិតានីតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា កិក្ខូ អាមន្តេសិ បណ្ឌិ-តោ កិក្ខវេ អានន្ទោ មហាបញ្ញោ កិក្ខវេ អានន្ទោ យត្រ ហិ នាម មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានិស្សតិ កុសិម្បិ នាម ការិស្សតិ អឌ្ឍកុ-សិម្បិ នាម ការិស្សតិ មណ្ឌលម្បិ នាម ការិស្សតិ អឌ្ឍមណ្ឌលម្បិ នាម ការិស្សតិ វិវដម្បិ នាម ការិស្សតិ

---

១ បស្សថ តុម្ហេតិ ទិស្សតិ ។

ចីវរក្ខន្ធកៈ រឿងព្រះអានន្ទត្ថេរ

ព្រះអានន្ទក្រាបបង្គំទូលថា ព្រះកុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា នែអានន្ទ អ្នកអាចចាត់ចែងចីវរបែបនេះដល់ភិក្ខុទាំងឡាយបានឬទេ ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គអាចធ្វើបាន ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទក្ខិណាគិរីជនបទ គួរដល់ពុទ្ធអធ្យាស្រ័យហើយក៏ទ្រង់យាងត្រឡប់មកក្រុងភគ្គនឹះវិញ ។ ខណៈនោះ ព្រះអានន្ទដ៏មានអាយុក៏បានចាត់ចែងចីវរដល់ភិក្ខុទាំងឡាយជាច្រើនរូប រួចហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទ្រង់ទតចីវរដែលខ្ញុំព្រះអង្គបានចាត់ចែងហើយចុះ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគក៏ទ្រើនូវធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ អានន្ទមានប្រាជ្ញាច្រើន ព្រោះថាពាក្យដែលតថាគតពោលហើយដោយសង្ខេប អានន្ទអាចដំរិះសេចក្តីដោយពិស្តារបាន ហើយចេះធ្វើសំពត់ឈ្មោះកុសិផង ធ្វើសំពត់ឈ្មោះអឌ្ឍកុសិផង ធ្វើសំពត់ឈ្មោះមណ្ឌលៈផង ធ្វើសំពត់ឈ្មោះអឌ្ឍមណ្ឌលៈផង ធ្វើសំពត់ឈ្មោះវិវដ្តៈផង

อนุปวชฺชญฺจ กาม กามสญฺญา กามเวยฺยาปาทญฺจ กามสญฺญา ถีนมิทฺธญฺจ กามสญฺญา กามุทฺธจฺจญฺจ กามสญฺญา กามวิจิกิจฺฉาญฺจ กามสญฺญา อิเมสุ ปญฺจสุ นีวรเณสุ ปหีเนสุ สมุจฺฉินฺเนสุ สมูหเตสุ สมุคฺฆาฏิเตสุ สมุคฺฆาฏิตตฺตา ปหีนตฺตา สมุจฺฉินฺนตฺตา สมูหตตฺตา สมุคฺฆาฏิตตฺตา ปฐมชฺฌานสมาปตฺติยา ปฐมชฺฌานสมาปตฺติยา ปหีนตฺตา สมุจฺฉินฺนตฺตา สมูหตตฺตา สมุคฺฆาฏิตตฺต

ធ្វើសំពត់ឈ្មោះអនុវាតដ្ឋៈផង ធ្វើសំពត់ឈ្មោះគីវេយ្យកៈផង ធ្វើសំពត់ឈ្មោះជង្ឃេយ្យកៈផង ធ្វើសំពត់ឈ្មោះពាហន្តៈផង ហើយសំពត់ខោះអានន្តិកក៏បានកាត់ជាច់ឲ្យសៅហ្មងដោយមុខកាំបិតឲ្យសមគួរដល់សមណៈ ឲ្យជាវេសមិនគួរច្បាស់ ដល់ពួកចោរជាសត្រូវ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសង្ឃដិកាត់ ខុទ្ទកសង្គៈកាត់ អន្តរវាសកៈកាត់ ។

(៥៦) គ្រានោះ ព្រះមានព្រះភាគគង់ក្នុងក្រុងរាជគ្រឹះគួរដល់ពុទ្ធអធ្យាស្រ័យ ហើយក៏ទ្រង់ចៀសចេរកាន់ចារិកក្រុងវេសាលី ។ ព្រះមានព្រះភាគទ្រង់យាងចេរកាន់ផ្លូវឡាយ ជាច្រើនោះក្រុងរាជគ្រឹះនឹងច្រើនោះក្រុងវេសាលី ក៏បានទតឃើញភិក្ខុទាំងឡាយច្រើនរូប មានចីវរវេចជាសំពាយ បានដាក់ផ្ចត់ចីវរលើក្បាលខ្លះ ដាក់ផ្ចត់ចីវរលើ-កខ្លះ ដាក់ផ្ចត់ចីវរលើចង្កេះខ្លះដើរមក លុះទតឃើញហើយ ព្រះដ៏មានព្រះភាគទ្រង់រិះគិតយ៉ាងនេះថា ពួកមោឃបុរសទាំងនេះវិលមកវិកសេចក្តីលោភក្នុងចីវរឆាប់ហ៊ាសណាស់ បើដូច្នោះគួរតថាគតចង់សីមាតាំងទុកនូវខេត្តដែនកុងចីវរដល់ភិក្ខុទាំងឡាយ ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់យាងចេរកាន់ចារិកដោយលំដាប់ ទើបបានដល់ទៅក្រុងវេសាលី ។

តត្រ សុទំ ភគវា វេសាលិយំ វិហរតិ គោតមកេ ចេតិ-
យេ ។ តេន ខោ បន សមយេន ភគវា សីតាសុ ហេ-
មន្តិកាសុ វត្តីសុ អន្តរដ្ឋកាសុ ហិមថាតសមយេ វត្តី
អជ្ឈោកាសេ ឯកចីវរោ និសីទិ ន ភគវន្តំ សីតំ
អហោសិ(๑) និក្ខន្តេ បឋមេ យាមេ សីតំ ភគវន្តំ អហោសិ
ទុតិយំ ភគវា ចីវរំ បារុបិ ន ភគវន្តំ សីតំ អហោសិ
និក្ខន្តេ មជ្ឈិមេ យាមេ សីតំ ភគវន្តំ អហោសិ តតិយំ
ភគវា ចីវរំ បារុបិ ន ភគវន្តំ សីតំ អហោសិ និក្ខន្តេ
បច្ឆិមេ យាមេ ឧទ្ធតេ អរុណេ នន្ទិមុខិយា រត្តិយា សីតំ
ភគវន្តំ អហោសិ ចតុន្នំ ភគវា ចីវរំ បារុបិ ន ភគវន្តំ
សីតំ អហោសិ ។ អថខោ ភគវតោ ឯតទហោសិ យេមំ
ខោ តេ កុលបុត្តា ឥមស្មិំ ធម្មវិនយេ សីតាលុកា
សីតភីរុកា តេបិ សង្កាន្តិំ តិចីវរេន យាបេតុំ យន្នូនា-
ហំ តិក្ខត្តុំ ចីវរេ សីមំ ពន្ធេយ្យំ មរិយាទំ ឋបេយ្យំ
តិចីវរំ អនុជានេយ្យន្តិ ។ **អថខោ** ភគវា ឯតស្មិំ និទានេ

---

๑ ន ភគវន្តំ សីតំ អហោសីតិ ភគវតោ សីតំ នាហោសីតិ (អដ្ឋកថា) ។

ឮបានឮថា ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងគោតមចេតិយទៀបក្រុងវេសាលីនោះ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគទ្រង់ចីវរតែមួយ គង់នៅក្នុងទីកណ្តាលវាលក្នុងវេលាយប់ ក្នុងសម័យមានទឹកសន្សើមធ្លាក់ប្លុះ ក្នុងរាត្រីខាងក្រោយដែលត្រជាក់នៅក្នុងហេមន្តរដូវ បិតនៅជាចន្លោះនៃខែមាឃនឹងខែផល្គុណ(១) ព្រះអង្គក៏មិនងោកឡើយ លុះបឋមយាមកន្លងទៅហើយទើបព្រះអង្គងោ ហើយព្រះអង្គទ្រង់ចីវរជាគំរប់ពីរ ព្រះអង្គក៏ជាត់ងោទៅ លុះមជ្ឈិមយាមកន្លងទៅហើយទើបព្រះអង្គងោ ហើយព្រះអង្គទ្រង់ដណ្តប់ចីវរជាគំរប់បី ព្រះអង្គក៏ជាត់ងោទៀត លុះបច្ឆិមយាមកន្លងទៅហើយ កាលអរុណរះឡើង រាត្រីក៏ភ្លឺច្បាស់ ។ ទើបព្រះអង្គងោ ព្រះអង្គទ្រង់ដណ្តប់ចីវរជាគំរប់ប្លន ព្រះអង្គក៏ជាត់ងោទៅ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់រិះគិតដូច្នេះថា កុលបុត្តទាំងឡាយណាដែលជាអ្នកងោជាប្រក្រតី ជាអ្នកខ្ជិលងោ កុលបុត្តទាំងនោះក៏អាចញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរ ៣ បាន បើដូច្នេះគួរតថាគតបង្ហាញសីមាហើយតាំងទុកនូវខេត្តដែនក្នុងចីវរ ហើយអនុញ្ញាតចីវរ ៣ ដល់ភិក្ខុទាំងឡាយ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា

---

๑ រឹមតំរិនោទនីដីកាថា រាត្រី ៨ គឺខាងចុងខែមាឃ ៤ រាត្រី ខាងដើមខែផល្គុណ ៤ រាត្រី ហៅជារាត្រីនោងជាចន្លោះនៃខែមាឃនឹងខែផល្គុណ ។

ฯ๓ สฺวายมตฺถปทวณฺณนา ฯ๓ ตตฺถ ตตฺถาติ ภุมฺมวจนนิทฺเทโส ฯ๓ ตสฺมาติ ตสฺมึ กาเล ฯ๓ ภควาติ ภาคฺยวนฺตาทิคุณโยคโต ฯ๓ เวสาลินฺติ เอวนามกนครวาสิโน อุทฺทิสฺส สงฺฆภาวโต ฯ๓ ปาติโมกฺขนฺติ ปาติโมกฺขสีลนฺติ ฯ๓ อุทฺทิสนฺตีติ ปกาสนฺติ ฯ๓ ตตฺถ ปาติโมกฺขนฺติ ปาติโมกฺขสีลนฺติ ฯ๓

ម្នាលភិក្ខុទាំងឡាយ កាលនេះតថាគត ចូលទៅកាន់ផ្លូវឆ្ងាយ ជាចន្លោះក្រុងភគ្គនឹងចន្លោះក្រុងវេសាលីហើយឃើញភិក្ខុច្រើនរូប មានចីវរវេចជាសំពាយដាក់ផ្តត់ចីវរលើកឈ្លខ្លះ ដាក់ផ្តត់ចីវរលើ-កខ្លះ ដាក់ផ្តត់ចីវរលើចង្កេះខ្លះដើរមក លុះឃើញហើយ តថាគតក៏មានសេចក្តីត្រិះរិះដូច្នេះថា ពួកមោឃបុរសទាំងនេះរឹលមករកសេចក្តីលោភកាន់ចីវរធាប់ពេកណាស់ បើដូច្នេះគួរតថាគតចង់សីមាតាំងទុកនូវខេត្តដែនកាន់ចីវរដល់ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាលនេះតថាគតទ្រង់ចីវរតែមួយអង្គុយនៅកាន់ទីកណ្តាលវាលកាន់រោយបង់កាន់សម័យមានទឹកសន្សើមជាក់ប៉ុន្តែកាន់ត្រីទាំងឡាយដែលត្រជាក់ នៅកាន់ហោមន្តរដូវ បិតនៅចន្លោះនៃខែមាឃនឹងខែផល្គុណ តថាគតក៏មិនរងាឡើយ លុះបឋមយាមកន្លងទៅហើយ ទើបតថាគតរងា តថាគតបានដណ្តប់ចីវរជាគំរប់ពីរ តថាគតក៏ចាត់រងាទៅ លុះមជ្ឈិមយាមកន្លងទៅហើយ ទើបតថាគតរងា តថាគតបានដណ្តប់ចីវរជាគំរប់បី ទើបតថាគតចាត់រងាទៅ លុះបច្ឆិមយាមកន្លងទៅហើយ អរុណរះឡើងត្រីក៏ភ្ញីព្រាង ។ ទើបតថាគតរងា តថាគតបានដណ្តប់ចីវរជាគំរប់ប្លន តថាគតក៏ចាត់រងាទៅ ម្នាលភិក្ខុទាំងឡាយ តថាគតក៏មានសេចក្តីត្រិះគិតដូច្នេះថា កាលធម្មវិន័យនេះ កុលបុត្តទាំងឡាយណា

ឥមស្មឹ ធម្មវិនយេ សីតាលុកា សីតភីរុកា តេបិ សវន្តីតិ តិចីវរេន យាបេតុំ យុត្តន្តាទិ កិក្ខុនំ ចីវរេ សិទ្ធេ ពាទ្ធេយ្យំ មរិយាទំ ឋបេយ្យ តិចីវរំ អធុជានេយ្យន្តិ អធុជានាទិ កិក្ខវេ តិចីវរំ ទ្វិក្ខុណំ(១) សន្ធាតិ ឯកចុំយំ ទុតិយសន្តិ ឯកចុំយំ អន្តរវាសកន្តិ ។

[៥៧] តេន ខោ បន សមយេន ឆព្ពគ្គិយា កិក្ខូ កសវតា តិចីវរំ អធុញ្ញាតន្តិ អញ្ញេនេវ តិចីវរេន គាមំ បវិសន្តិ អញ្ញេនេវ តិចីវរេន អារាមេ អច្ឆន្តិ អញ្ញេនេវ តិចីវរេន ឧមាគំ ទិតវន្តិ ។ យេ តេ កិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឆដ្ឋាយន្តិ ទីយន្តិ វិហាបេន្តិ កថំ ហិ នាម ឆព្ពគ្គិយា កិក្ខូ អតិរេកចីវរំ ធារេស្សន្តីតិ ។ អថខោ តេ កិក្ខូ កសវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ កសវ ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា កិក្ខូ អាមន្តេសិ ន កិក្ខវេ អតិរេកចីវរំ ធារេតព្ពំ យោ ធារេយ្យ យថាធម្មោ ការេតព្ពោតិ ។ តេន ខោ បន

---

(១) ម. ទិគុណំ ។

ដែលជាអ្នកនោជាប្រក្រតី ជាអ្នកខ្វាចរនោ កុលបុត្តទាំងនោះអាចញុំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរ៣ បើដូច្នោះគួរតថាគតចងសីមាតាំងទុកខ្លះខេត្តដែនក្នុងចីវរ គួរអនុញ្ញាតចីវរ៣ ដល់កិក្ខុទាំងឡាយ ម្នាលកិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីវរ៣ គឺ សង្ឃាដិពីរជាន់ ឧត្តរាសង្គៈ (ចីពរ) ១ ជាន់ សម្បជ្ជ ១ ជាន់ ។

(៩៧) សម័យនោះឯង ពួកឆព្វគ្គិយកិក្ខុដឹងថា ចីវរ៣ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតរួចហើយ ។ ក៏នាំគ្នាចូលទៅកាន់ស្រុកដោយចីវរ៣ ដទៃទៀត នៅក្នុងវត្តដោយចីវរ៣ដទៃទៀត ចុះទៅកាន់កំពង់ជាទីស្រង់ទឹកដោយចីវរ៣ដទៃទៀត ។ កិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ កិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកឆព្វគ្គិយកិក្ខុមិនសមបើនឹងទ្រទ្រង់អតិរេកចីវរសោះ ។ កិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងពេលនោះរួចទ្រង់ត្រាស់ហៅកិក្ខុទាំងឡាយមកថា ម្នាលកិក្ខុទាំងឡាយ កិក្ខុមិនត្រូវទ្រទ្រង់អតិរេកចីវរទេ កិក្ខុណាទ្រទ្រង់ កិក្ខុនោះត្រូវនិយនឲ្យធ្លាក់តាមធម៌ ។ សម័យនោះ

សមយេន អាយស្មតោ អានន្ទស្ស អតិរេកចីវរំ ឧប្បន្នំ
ហោតិ ។ អាយស្មា ច អានន្ទោ តំ ចីវរំ អាយស្មតោ
សារីបុត្តស្ស ទាតុកាមោ ហោតិ ។ អាយស្មា ច
សារីបុត្តោ សាកេតេ វិហរតិ ។ អថខោ អាយស្មតោ
អានន្ទស្ស ឯតទហោសិ ភគវតា បញ្ញត្តំ ន អតិរេ-
កចីវរំ ជារេតព្ពន្តិ ឥទញ្ច មេ អតិរេកចីវរំ ឧប្បន្នំ
អហញ្ចិមំ ចីវរំ អាយស្មតោ សារីបុត្តស្ស ទាតុកាមោ
អាយស្មា ច សារីបុត្តោ សាកេតេ វិហរតិ កថំ នុ ខោ
មយា បដិបជ្ជិតព្ពន្តិ ។ អថខោ អាយស្មា អានន្ទោ
ភគវតោ ឯតមត្ថំ អារោចេសិ ។ តីវចិរំ បជានន្ត
សារីបុត្តោ អាគច្ឆិស្សតីតិ ។ ឆវមំ វា ភគវា ចិវសំ
ឧសមំ វាតិ ។ អថខោ ភគវា ឯតស្មិំ និទានេ ឯតស្មិំ
បការណេ ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជា-
នាមិ ភិក្ខវេ ឧសាហាបរមំ អតិរេកចីវរំ ជារេតុន្តិ ។
តេន ខោ បន សមយេន ភិក្ខូនំ អតិរេកចីវរំ ឧប្បន្នំ
ហោតិ ។ អថខោ ភិក្ខូនំ ឯតទហោសិ តាវ

អតិរេកចីវរជាន កើតឡើងដល់ព្រះអានន្ទដ៏មានអាយុ ។ ឯព្រះអានន្ទដ៏មានអាយុ ក្រាបថ្វាយបង្គំប្រគេនចីវរនោះ ទៅព្រះសារីបុត្តដ៏មានអាយុ ។ ព្រះសារីបុត្តដ៏មានអាយុ ក៏គង់នៅឯក្រុងសាកេត ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីនឹកគិតដូច្នេះថា ព្រះមានព្រះភាគ ជានបញ្ញត្តថា កិក្ខុមិនត្រូវឲ្យឆ្លងអតិរេកចីវរទេ ក៏ឯអតិរេកចីវរនេះ កើតឡើងដល់អាត្មាអញហើយ តែថាអាត្មាអញចង់ប្រគេនចីវរនេះ ទៅព្រះសារីបុត្តដ៏មានអាយុ ឥឡូវព្រះសារីបុត្តដ៏មានអាយុ គង់នៅឯក្រុងសាកេត តើអាត្មាអញត្រូវប្រតិបត្តិដូចម្តេច ។ ខណៈនោះ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែអានន្ទ ចុះសារីបុត្តនៅយូរប៉ុន្មានថ្ងៃទៀតទើបចានមក ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ព្រះសារីបុត្តមុខជានឹងមកក្នុងថ្ងៃទី៨ ឬក្នុងថ្ងៃទី ១០ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅកិក្ខុទាំងឡាយមកថា ម្នាលកិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកិក្ខុទាំងឡាយទ្រទ្រង់អតិរេកចីវរកំណត់ត្រឹម ១០ ថ្ងៃ ។ សម័យនោះ អតិរេកចីវរកើតឡើងដល់កិក្ខុទាំងឡាយ ។ លំដាប់នោះ កិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា

ន្តុ ខោ អម្ហេហិ[1] អតិវេកចីវរេ បដិបជ្ជិតព្ពន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អតិវេកចីវរំ វិកប្បេតុន្តិ ។

[៥៨] អថខោ ភគវា វេសាលិយំ យថាភិរន្តំ វិហរិត្វា យេន ពារាណសី តេន ចារិកំ បក្កាមិ អនុបុព្ពេន ចារិកំ ចរមានោ យេន ពារាណសី តទវសរិ ។ តត្រសុទំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ អន្តរាសនោ ជិណ្ណោ ហោតិ ។ អថខោ តស្ស ភិក្ខុនោ ឯតទហោសិ ភគវតា តិចីវរំ អនុញ្ញាតំ ទ្វិក្ខុណា សង្ឃាដិ ឯកច្ចិយោ ទុត្តរាសង្គោ ឯកច្ចិយោ អន្តរាសនោ អយញ្ច មេ អន្តរាសនោ ជិណ្ណោ យន្នូនាហំ អក្កន្តំ អក្ខបេយ្យំ សមន្តតោ ទុបដ្ដំ ភវិស្សតិ មជ្ឈ ឯកច្ចិយន្តិ ។ អថខោ សោ ភិក្ខុ អក្កន្តំ អក្ខបេសិ ។ អទ្ទសា ខោ ភគវា សេនាសនចារិកំ អាហិណ្ឌន្តោ តំ ភិក្ខុំ អក្កន្តំ អក្ខបេន្តំ ទិស្វាន

---

១ ឧភោបិយោគេកេ អយំ ចាហោ ន ហោតិ ។

យើងគួរប្រតិបត្តិកងអតិរេកចីវរដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរក្សាអតិរេកចីវរទុកបាន ។

(៥៨) គ្រានោះ ព្រះដ៏មានព្រះភាគគង់ក្នុងក្រុងវេសាលីគួរដល់ពុទ្ធអធ្យាស្រ័យហើយក៏ទ្រង់យាងទៅកាន់ចារិកក្រុងពារាណសី តាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងពារាណសី ។ បានឮមកថា ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងឥសិបតនមិគទាយវនទៀបក្រុងពារាណសីនោះ ។ សម័យនោះ ភិក្ខុ ១ រូបមានសង្ឃាដិ្ដ ។ វេលានោះ ភិក្ខុនោះមានសេចក្តីត្រិះរិះដូច្នេះថា ចីវរ ៣ គឺ សង្ឃាដិ ២ ជាន់ ឧត្តរាសង្គ ១ ជាន់ សង្ឃាដិ ១ ជាន់ ព្រះដ៏មានព្រះភាគបានអនុញ្ញាតរួចហើយ ឯសង្ឃាដិរបស់អាត្មាអញដ្ឋិ បើដូច្នោះគួរអាត្មាអញប៉ះនូវបម្នះ កាលបើដូច្នោះសង្ឃាដិនោះនឹងទៅជា ២ ជាន់ដោយជុំវិញ កណ្តាល ១ ជាន់ ។ វេលានោះ ភិក្ខុនោះក៏បានប៉ះនូវបម្នះ ។ ព្រះដ៏មានព្រះភាគបានយាងទៅកាន់សេនាសនចារិកក៏បានទតឃើញភិក្ខុនោះកំពុងប៉ះនូវបម្នះ លុះទតឃើញ

យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ
ឯតទវោច កឹ នុ ខ្វំ ភិក្ខុ ករោសីតិ ។ អក្កន្ទុំ ករកា
អច្ចុបេមីតិ ។ សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ
អក្កន្ទុំ អច្ចុបេសីតិ ។ អថខោ ករកា ឯតស្មឹ និទានេ
ឯតស្មឹ បករណេ ធម្មឹ ភាសំ ភិក្ខូ អាមន្តេសិ
អនុជានាមិ ភិក្ខវេ អហិតានំ ទុស្សានំ អហិតករប្បានំ
ទ្វិក្ខុណាំ សង្ឃាដឹ ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្ត-
រវាសកំ ឧត្តុទ្ធានំ ទុស្សានំ ចតុក្ខុណាំ សង្ឃាដឹ ទ្វិក្ខុ-
ណាំ ឧត្តរាសង្គំ ទ្វិក្ខុណាំ អន្តរវាសកំ បំសុកូលេ យោ-
វេទត្តំ ចាបណិកេ ទុស្សហេរោ ករណីយោ អនុជានាមិ
ភិក្ខវេ អក្កន្ទុំ តុដ្ឋំ ឯវដ្ដិកំ ករណ្ឌុសកំ ធនុក្កម្មត្តំ ។

ហើយក៏ទ្រង់យាងចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយទ្រង់ត្រាស់នឹងភិក្ខុនោះដូច្នេះថា នែភិក្ខុ អ្នកធ្វើអ្វី ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គប៉ះនូវបម្នះ ។ ព្រះដ៏មានព្រះភាគទ្រង់តបថា ប្រពៃហើយ ។ ភិក្ខុ ប្រពៃហើយភិក្ខុ អ្នកបានប៉ះនូវបម្នះ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគក៏ទ្រង់ធ្វើនូវធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ កាលបើសំពត់នៅថ្មោងថ្មសំពត់ដែលគេចោកលាងម្តងហើយ តថាគតអនុញ្ញាត (ឲ្យអ្នកទាំងឡាយធ្វើ) សង្ឃាដិ ២ ជាន់ ឧត្តរាសង្គៈ ១ ជាន់ សង្ឃាដិ ១ ជាន់ (បើ) សំពត់ដែលគេរើឡើងពីរដូវ (គឺសំពត់ចាស់) តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយធ្វើសង្ឃាដិ ៤ ជាន់ ឧត្តរាសង្គៈ ២ ជាន់ សង្ឃាដិ ២ ជាន់ អ្នកទាំងឡាយគួរធ្វើនូវសេចក្តីប្រឹងប្រែងស្វែងរកសំពត់បង្សុកូលសំពត់ធ្លាក់ចុះកង់ពនផ្សារតាមត្រូវការ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវបម្នះ[1] នូវការដុល នូវក្រវិលកណ្តាំ នូវកណ្តាំ នូវការធ្វើឲ្យមាំ[2]

---

១ បានដល់សំពត់ដែលភិក្ខុប៉ះត្រង់កន្លែងធ្លុះឬត្រង់កន្លែងដែលខ្វះកាត់ចេញ ។ ២ បានដល់សំពត់ដែលភិក្ខុប៉ះត្រង់កន្លែងដែលមិនបានកាត់ចេញ ។

[៥៩] អថខោ ភគវា ពាហណាសិយំ យថាភិរន្តំ
វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្ពេន
ចារិកំ ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ
ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស
អារាមេ ។ អថខោ វិសាខា មិគារមាតា យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ
និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វិសាខំ មិគារមាតរំ
ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ
សមុត្តេជេសិ សម្បហំសេសិ ។ អថខោ វិសាខា
មិគារមាតា ភគវតា ធម្មិយា កថាយ សន្ទស្សិតា
សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវន្តំ ឯត-
ទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ
សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភា-
វេន ។ អថខោ វិសាខា មិគារមាតា ភគវតោ អធិវាសនំ

(៥៩) គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្រុងពារាណសីគ្នា ដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់យាងទៅកាន់ចារិកក្រុងសាវត្ថី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថីនោះ ។ បានឮមកថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅវត្តព្រះជេតពនរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថីនោះ ។ លុះនោះ នាងវិសាខាមិគារមាតាបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយនៅក្នុងទីដ៏សមគួរ ។ កាលនាងវិសាខាមិគារមាតាអង្គុយនៅក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់នាងវិសាខាមិគារមាតាដែលអង្គុយនៅក្នុងទីសមគួរហើយ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លុះដាប់នោះ នាងវិសាខាមិគារមាតា លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថារួចហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលកត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែកជាមួយនឹងភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លុះដាប់នោះ នាងវិសាខាមិគារមាតាបានដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តហើយ

วิธิตฺวา ฉฑฺฑยาสนา ภควนฺตํ อภิวาเทตฺวา ปทกฺขิณํ
กตฺวา ปกฺกามิ ฯ เตน ขเณ ปน สมเยน ตสฺสา
รตฺติยา อจฺจเยน จาตุทฺทีปิกา มหาเมฆา วสฺสนฺติ ฯ
อถโข ภควา ภิกฺขู อามนฺเตสิ ยถา ภิกฺขเว เอตรหิ
วสฺสติ เอวํ ปุเรปิ วสฺสติ ปุเรสฺสปิ ภิกฺขเว ภิกฺขู-
เว กายํ อยํ ปฐมิกา จาตุทฺทีปิกา มหาเมฆา-
โยติ ฯ เอวํ วุตฺเตปิ โข เต ภิกฺขู ภควนฺตเมว ปฏิสฺสุณิตฺวา
ตาทิสา ขาทนียา ยาทิสา ราชูนญฺจ ราชมหามตฺตานญฺจ
ตาทิสญฺจ สูปพฺยญฺชนญฺจ ปฏิปาเทสิ ฯ อถโข ภิกฺขเว
ธนญฺชานี พฺราหฺมณี กุมารสฺส ปตฺตเมวาสึ ฉิทฺทา[๑]เว
เย มาตาปิตโร ยญฺญตฺถาย มาตาปิตโร อเสฺสยฺยุนฺติ ฯ

---

๑ ฉ. ฉิทฺทาวฏฺฏา ฯ

ដោយពាក្យថា ព្រះករុណាវិសេសព្រះអង្គ ហើយក៏នៅនាំយកស្ពៃចុកឆ្នាំ
ដែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសីមក ។ ម្នាលភិក្ខុទាំងឡាយ
គ្រានោះ ស្ពៃចុកឆ្នាំដែនកាសីព្រះនាមព្រហ្មទត្តទ្រង់បង្គាប់នៅពួកមនុស្ស
ទាំងឡាយថា នែនាយទាំងឡាយ បើដូច្នោះអ្នកទាល់គ្នាចូរនាំគ្នាចាប់
ស្ពៃចុកឆ្នាំដែនកោសលឈ្មោះទីឃីតិព្រមទាំងមហេសីចងឲ្យមានដើមដៃ
នៅខាងក្រោយ(១) ឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយកោរក្បាលឲ្យរលីងចេញ
រួច(ត្រែវទូង)ស្គរ ដែលមានសំឡេងឮខ្ទំងហើយនាំបណ្តើរដុំវិញសព្វថ្ងៃចុក
សព្វផ្លូវត្រែឡែងកែង រួចនាំចេញតាមទ្វារខាងត្បូងហើយកាប់
ជា ៤ កំណាត់កប់នៅកន្លែងណៅគ្រប់ទិសទាំង ៤ ជាខាងត្បូងនៃក្រុង ។
ម្នាលភិក្ខុទាំងឡាយ ឯមនុស្សទាំងនោះបានទទួលព្រះឱង្ការស្ពៃចុកឆ្នាំដែន
កាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយក៏នាំ
គ្នាចាប់ស្ពៃចុកឆ្នាំដែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសីឲ្យមានដើម
ដៃនៅខាងក្រោយឲ្យខ្ជាប់ដោយខ្សែដ៏មាំហើយកោរក្បាលឲ្យរលីងចេញ
ហើយ (ទូង) ស្គរដែលមានសំឡេងឮខ្ទំង រួចនាំបណ្តើរដុំវិញសព្វថ្ងៃចុក
សព្វផ្លូវត្រែឡែងកែង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទីឃាវុកុមារ
មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញខានឃើញមាតាបិតាយូរណាស់
ហើយ បើដូច្នោះគួរតែអាត្មាអញទៅមើលមាតាបិតាបានម្តងសិន ។

---

១ គឺចងស្មាបសេក បណ្តើរអាក្រាស ។

อถ โข ภิกฺขเว ธีตา กุมารี พาหณาสึ ปวิสิตฺวา อฑฺฒสฺส มาตาปิตโร อุปฏฺฐาย วฑฺฒยา ปฏิฺญาย ตาย- ยาจิตา ตณฺฑุลปฺปมาณิกา ขาริกา ขารสฺสเรน ปณาเมน วฏิยาย วฏิยึ สิงฺฆาฏเกน สิงฺฆาฏกึ ปริเณตฺวา นิสฺสาย เยน มาตาปิตโร เตนุปสงฺกมิ ฯ อฑฺฒสา โข ภิกฺขเว ธีตา กุมารี โกสลกสฺส ธีตา กุมารึ อฺญาตเร ปจฺจนฺตชนปเท นิสฺสาย ธีตา กุมารึ ฌตนเกจ มา โข ตฺวึ ตาต ธีตา ธีตึ ปสฺส มา รสฺสึ ธ มา ตาต ธีตา เวเรน เวเร สมฺมฺติ อเวเรน มา ตาต ธีตา เวเร สมฺมฺติ ฯ ฌึ ปุตฺเต ภิกฺขเว เต มนุสฺสา ธีตรึ ตสฺส โกสลกสฺส ธีตรึ ฌตนเกปุ ขุมฺมตฺตาย อยึ ธีตา โกสลกสฺส ปิฺญาปิตา โข ฯมสฺส ธี- ตา กึ อยึ ฌมาหา มา โข ตฺวึ ตาต ธีตา ธีตึ ปสฺส มา รสฺสึ ธ มา ตาต ธีตา เวเรน เวเร สมฺมฺติ อเวเรน มา ตาต ธีตา เวเร สมฺมฺติ ฯ

ម្នាលគហបតីទាំងឡាយ លំដាប់នោះ ទីឃាវុកុមារចូលទៅគ្រែឆត្តពាក្យណាស៊ីហើយ ក៏ឃើញមាតាបិតាដែលគេកំពុងតែចងស្បៃសេតជាប់ដោយខ្សែដ៏មាំ គោរកឡាលឲ្យរលើងចេញ (ទូង) ស្គរដែលមានសំឡេងពុំខ្លាំង ហើយនាំបណ្តើរដុំវិញសព្វច្រក សព្វផ្លូវត្រែឡើងកែង លុះឃើញហើយក៏ចូលទៅកាមាតាបិតា។ ម្នាលគហបតីទាំងឡាយ ឯស្តេចកុងដែនកោសលព្រះនាមទីឃីតិក្រែងតទៅឃើញទីឃាវុកុមារមកអំពីចម្ងាយ លុះឃើញហើយក៏មានព្រះឱង្ការទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ។ ម្នាលគហបតីទាំងឡាយ កាលបើស្តេចនោះមានព្រះឱង្ការយ៉ាងនេះហើយ ពួកមនុស្សទាំងនោះក៏ពោលពាក្យនេះនឹងស្តេចកុងដែនកោសលព្រះនាមទីឃីតិថា ស្តេចកុងដែនកោសលព្រះនាមទីឃីតិនេះឆ្គួតនិយាយផ្តេសផ្តាសទេតើ នរណាឈ្មោះទីឃាវុ (ជាកូន) របស់ស្តេចនេះ ស្តេចនេះនិយាយទៅនឹងនរណាយ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ។

ชาตา ภาณา ขุทฺทกา วิปฺปลปิตา อปิจ ยา
วิญฺ สา วิการาสฺสาตีติ ฯ ขุทฺทิยมฺปิ ขา ภิกฺขเว ฯ เป ฯ
ตติยมฺปิ ขา ภิกฺขเว ธิยีติ โคสลราชา ธิยาปุ
กุมาริ ปิตรา ภาเต มา ขา ตุ์ ตาต ธิยาปุ ธิยิ
ปสฺส มา รสฺสุ ณ ปิ ตาต ธิยาปุ เวเร เวร
สมฺปชฺชิ อเวเร ปิ ตาต ธิยาปุ เวร สมฺปชฺชีติ ฯ
ตติยมฺปิ ขา ภิกฺขเว เต มนุสฺสา ธิยีติ โคส-
ลราชาน ปิตรา ภาเต ขุทฺทกา อยิ ธิยีติ โคส-
ลราชา วิปฺปลปติ โคา ปมสฺส ธิยาปุ กิ อยิ
ปาภาติ มา ขา ตุ์ ตาต ธิยาปุ ธิยิ ปสฺส มา
รสฺสุ ณ ปิ ตาต ธิยาปุ เวเร เวร สมฺปชฺชิ อเวเร
ปิ ตาต ธิยาปุ เวร สมฺปชฺชีติ ฯ ชาตา ภาณา
ขุทฺทกา วิปฺปลปิตา อปิจ ยา วิญฺ สา

ស្តេចទីឃីតិនោះតបទៅវិញថា នែនាយ យើងមិនមែនឆ្កួតនិយាយផ្តេសផ្តាសទេ បើនរណាជាអ្នកប្រាជ្ញ អ្នកនោះទើបថ្លែងសេចក្តីបាន ។ ម្នាលភិក្ខុទាំងឡាយ ស្តេចកង់ដែនកោសលព្រះនាមទីឃីតិមានព្រះទ្រង្វាន់ទៅនឹងទីឃាវុកុមារជាគំរប់ពីរដងផង ។បេ។ ម្នាលភិក្ខុទាំងឡាយ ស្តេចកង់ដែនកោសលព្រះនាមទីឃីតិមានព្រះទ្រង្វាន់ទៅនឹងទីឃាវុកុមារជាគំរប់បីដងផង យ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចង់ពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចង់ពៀរ ។ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងនោះក៏បាននិយាយពាក្យនេះនឹងស្តេចកង់ដែនកោសលព្រះនាមទីឃីតិជាគំរប់បីដងទៀតថា ស្តេចកង់ដែនកោសលព្រះនាមទីឃីតិនេះឆ្កួតនិយាយផ្តេសផ្តាសទេតើ នរណាឈ្មោះទីឃាវុ(ជាកូន)របស់ស្តេចនេះ ស្តេចនេះនិយាយទៅនឹងនរណា យ៉ាងនេះថា នែទីឃាវុកូន អ្នកកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចង់ពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចង់ពៀរ ។ ស្តេចនោះទ្រង់តបទៅវិញថា នែនាយ យើងមិនមែនជាមនុស្សឆ្កួតនិយាយផ្តេសផ្តាសទេ ប៉ុន្តែបើនរណាជាអ្នកប្រាជ្ញ អ្នកនោះ

វិភាវេស្សតីតិ ។ អថខោ តិក្ខត្តុំ តេ មនុស្សា ឆិយឹតំ
កោសលរាជានំ សបជាបតិកំ រជិយាយ រជ្ជំ សង្ឆា-
ដេត្វា សង្ឆដកំ បរិនេត្វា ឧក្កំណោន ង្ហាបេន ឯក្កា-
មេត្វា ឧក្កំណាតោ ឧភរស្ស បត្តុជា ឯន្ធិត្វា បត្តុន្ធិសា
ពិលានិ ឯក្កិបិត្វា កុម្ភំ បវេត្វា បក្កមឹសុ ។ អថខោ
តិក្ខត្តុំ ទីឃាវុ កុមារោ ពាហណាសឹ បរិសិត្វា សុវុំ
ឆិបរិត្វា កុម្ភិយេ ចាយេសិ ។ យថា តេ មត្តា អហោ-
សុំ បតិតា អថ កដ្ឋានិ សង្កឌ្ឍិត្វា មាតាបិតូនំ សរីរំ
ឯតកំ អាវេបេត្វា អគ្គិំ ឧត្វា បញ្ចលិកោ តិក្ខត្តុំ ឯតកំ
បទក្ខិណំ អកាសិ ។ តេន ខោ បន តិក្ខត្តុំ សមយេន
ព្រហ្មទត្តោ កាសីរាជា ឧបរិបប្បាសាទវរតលោ ហោតិ ។
អទ្ទសា ខោ តិក្ខត្តុំ ព្រហ្មទត្តោ កាសីរាជា ទីឃាវុំ
កុមារំ បញ្ចលិកំ តិក្ខត្តុំ ឯតកំ បទក្ខិណំ ករោន្តំ
ទិស្វានស្ស ឯតទហោសិ ឯិស្សរិយំ ខោ សោ មនុស្សា
ទីឃីតិស្ស កោសលរញ្ញោ ញាតិ វា សាលោហិតោ
វា អហោ មេ អនត្តោ[1] ន ហិ នាម មេ កោធំ

---

๑ អនត្តកោតិ កត្តុំ ចោត្តុំ ទិស្សតិ ។

ដើមថ្ងៃសេចក្តីថាន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មនុស្សទាំងនោះក៏នាំបណ្តើរស្តេចកងវែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសីសៅសព្វប្រកសព្វផ្លូវត្រែឆ្លងកែង ហើយចេញទៅតាមទ្វារខាងត្បូង ហើយកាត់ខ្លួនជា ៤ កំណាត់ រួចកប់កងរណ្តៅគ្រប់ទិសទាំង ៤ ជាខាងត្បូងនៃព្រះនគរហើយទុកពួកពល (ឲ្យនៅថែទាំ) រួចថយចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារចូលទៅកាន់គ្រែងពាកណាសី ហើយក៏នាំយកសុភមកបំផឹកពួកពល (ទាំងនោះ) ។ ពួកពលទាំងនោះស្រវឹងដួលដេកទៅកាលណា ទីឃាវុកុមារក៏ប្រមូលកំណាត់ឈើ ហើយលើកសរីរៈមាតាបិតាជាក់លើដើងភ្លើងរួចបូជាភ្លើង ហើយផ្តងអញ្ជលីធ្វើប្រទក្សិណដើងភ្លើង ៣ ដុំ ។ ម្នាលភិក្ខុទាំងឡាយ ចួនជាពេលនោះ ស្តេចកងវែនកាសីព្រះនាមព្រហ្មទត្ត ទ្រង់គង់ទៅលើប្រាសាទដ៏ប្រសើរឮជ័យខាងលើ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចកងវែនកាសីព្រះនាមព្រហ្មទត្ត ឮនទតទៅឃើញទីឃាវុកុមារកំពុងតែផ្តងអញ្ជលីធ្វើប្រទក្សិណដើងភ្លើង ៣ ដុំ លុះឃើញហើយក៏ទ្រង់ត្រិះរិះយ៉ាងនេះថា មនុស្សនោះឮសាជាញាតិឬជាសាលោហិតរបស់ស្តេចកងវែនកោសលឈ្មោះទីឃីតិហើយតុហ្មសេចក្តីវិនាស(ព្រោះបុរសនេះគង់នឹងមាន)ដល់អាត្មាអញ មិនសមបើ

อาโรเจสฺสตีติ ฯ อถ โข ภิกฺขเว ธีตา กุมาริ อญฺญํ
ทณฺฑา ยาวทตฺถํ ภุญฺชิตฺวา เวทิตฺวา วิปฺปฺ ปุญฺชิตฺวา[๑] ภา-
ชนานิ วิสิญฺจิตฺวา อนฺตปุรสฺส สามนฺตา ปาสาทํ
ทณฺฑา ปาตราสมกาสิ ฯเปฯ ปาตราสมกาสิ สมฺปฺ
สิญฺจิตฺวาติ ฯ เตนหิ ภิกฺขเว ภิกฺขุสงฺฆสฺส ภิกฺขเว
อถ โข ภิกฺขเว ธีตา กุมาริ ราชิยา ปจฺจูสสมยํ
ปจฺจุฏฺฐาย ปาสาทานิ มญฺญา สเรน ตายิ วิญฺญา
ภาเนสิ ฯ อสฺโสสิ โข ภิกฺขเว พฺรหฺมทตฺโต กา-
สีภชา ราชิยา ปจฺจูสสมยํ ปจฺจุฏฺฐาย ปาสาทานิ
มญฺญา สเรน ตีตา วิญฺญา ภาณิตา สุตฺวาน มนุสฺส
ปุจฺฉิ กา ภิกฺขเว ราชิยา ปจฺจูสสมยํ ปจฺจุฏฺฐาย
ปาสาทานิ มญฺญา สเรน ตายิ วิญฺญา ภาเนสี-
ติ ฯ อมุกสฺส เทว ปาตราสมกาสิ สมฺปฺ อนฺตปุรสฺส ภิกฺขเว
ราชิยา ปจฺจูสสมยํ ปจฺจุฏฺฐาย ปาสาทานิ มญฺญา
สเรน ตายิ วิญฺญา ภาเนสีติ ฯ เตนหิ ภิกฺขเว

๑ ปาฬิยํ มุญฺจิตฺวาติ ทกฺขิณ ปาตราเส ทิสฺสติ ฯ

គ្មាននរណាមួយជ្រាបអាត្មាអញសោះ ។ ម្នាលគហបតីទាំងឡាយ គ្រានោះ ទីឃាវុកុមារទៅឯព្រៃហើយ ទ្រុឡុងលូតលួញយ៉ាងអស់ចិត្តរួចដួតទឹកភ្នែកហើយត្រឡប់ចូលទៅក្នុងក្រុងពារាណសីវិញ ក៏ទៅឯពេងដំរីទៀបព្រះពុទ្ធដំរីហើយនិយាយពាក្យនេះនឹងហ្វូងដំរីថា នែអ្នកហ្វូងដំរី ខ្ញុំចង់រៀនសិល្បៈ (អំពីអ្នកតើបានឬទេ) ។ ឯហ្វូងដំរីនោះនិយាយតបថា នែនាយមាណព បើដូច្នោះចូរអ្នករៀនចុះ ។ ម្នាលគហបតីទាំងឡាយ វេលានោះ ទីឃាវុកុមារក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ក៏ស្រែកច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងពេងដំរី ។ ម្នាលគហបតីទាំងឡាយ ឯស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តបានទ្រង់ព្រះសណ្តាប់ចង្វែងនឹងពិណដែលទីឃាវុកុមារក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រីហើយច្រៀងច្របកបដោយសំឡេងយ៉ាងពីរោះក្នុងពេងដំរី លុះទ្រង់ព្រះសណ្តាប់រួចហើយក៏ទ្រង់ត្រាស់សួរមនុស្សទាំងឡាយថា នែនាយ នរណាក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ក៏ច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងពេងដំរី ។ មនុស្សទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាជ្រាប មាណពជាកូនសិស្សរបស់ហ្វូងដំរីឯណោះ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ក៏ច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងពេងដំរី ។ ស្តេចនោះទ្រង់ត្រាស់ថា នែនាយ បើដូច្នោះ

តំ មាណវកំ អានេថាតិ ។ ឃំ នេកតិ ខោ កិក្ខវេ តេ
ពន្ធុសុទ្ធា ព្រហ្មទត្តស្ស ការាសីរញ្ញោ បដិសុណិត្វា ទីឃាវុំ
កុមារំ អានេសុំ ។ អថខោ កិក្ខវេ ព្រហ្មទត្តោ កា-
សីរាជា ទីឃាវុំ កុមារំ ឯតទវោច តុំ កណោ មាណវក
រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ បាតំសាលាយំ មញ្ជា
សវេន តាយិ វីណាញ្ច ភានេសីតិ ។ ឃំ នេកតិ ។
នេនហិ កណោ មាណវក តាយ សស្សុ វីណាញ្ច ភានេហីតិ ។
ឃំ នេកតិ ខោ កិក្ខវេ ទីឃាវុ កុមារោ ព្រហ្មទត្តស្ស
ការាសីរញ្ញោ បដិសុណិត្វា អាភណាបេត្វោ មញ្ជា
សវេន តាយិ វីណាញ្ច ភានេសិ ។ អថខោ កិក្ខវេ
ព្រហ្មទត្តោ ការាសីរាជា ទីឃាវុំ កុមារំ ឯតទវោច តុំ
កណោ មាណវក មំ ឧបដ្ឋហាតិ ។ ឃំ នេកតិ ខោ
កិក្ខវេ ទីឃាវុ កុមារោ ព្រហ្មទត្តស្ស ការាសីរញ្ញោ
បច្ចុស្សោសិ ។ អថខោ កិក្ខវេ ទីឃាវុ កុមារោ ព្រហ្ម-
ទត្តស្ស ការាសីរញ្ញោ បុព្ពុដ្ឋាយី អហោសិ បច្ចានិទាតី

អ្នកទាំងឡាយចូរនាំមាណពនោះមក ។ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងនោះទទួលស្តាប់ព្រះចុន្ទារស្តេចកន្លងវែនកាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយក៏នាំទីឃាវុកុមារមក ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចកន្លងវែនកាសីព្រះនាមព្រហ្មទត្តទ្រង់មានព្រះចុន្ទារទៅទទឹងទីឃាវុកុមារយ៉ាងនេះថា នែនាយមាណព អ្នកឯងរកែកខ្លីឯងកន្លងបច្ចុសសម័យនៃពត្រី ក៏ច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង កន្លងពេងដំរីមែនឬ ។ ទីឃាវុកុមារក្រាបទូលថា ព្រះករុណាវិសេស ។ ស្តេចនោះទ្រង់ត្រាស់ថា នែនាយមាណព បើដូច្នោះចូរអ្នកឯងច្រៀងហើយដេញពិណឲ្យយើងស្តាប់មើល ។ ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារទទួលស្តាប់ព្រះចុន្ទារស្តេចកន្លងវែនកាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយចង់ឲ្យស្តេចជ្រោសជ្រាណា ទើបស្រែកច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ។ ម្នាលភិក្ខុទាំងឡាយ ខណនោះ ស្តេចកន្លងវែនកាសីព្រះនាមព្រហ្មទត្តមានព្រះចុន្ទារទៅទទឹងទីឃាវុកុមារយ៉ាងនេះថា នែនាយមាណព ចូរអ្នកឯងនៅបម្រើយើងចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារក៏ទទួលស្តាប់ព្រះចុន្ទារស្តេចកន្លងវែនកាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារក៏ចាននក្រោកមុនដេកក្រោយទំនទទួលស្តាប់

ภิกฺขาจริยสฺสาปิ มยฺหาจริยสฺสาปิ ปิยภาวญฺจ ฯ อถ ขฺวาหํ ภิกฺขเว พฺรหฺมทตฺตสฺส กาสิราชสฺส ธีตรญฺจ กุมารญฺจ ฉฑฺเฑตฺวา อญฺญตรสฺมึ วิสฺสาสิกฏฺฐาเน ปเทสญฺจ ฯ อถ ขฺวาหํ ภิกฺขเว พฺรหฺมทตฺตสฺส กาสิราชสฺส ธีตรญฺจ กุมารญฺจ ฉฑฺเฑตฺวา เตนหิ ภเณ มาณวกา รถํ โยเชถาติ มิตฺตานิ ปฏิสฺสุณิตฺวา ฯ ฯเปฯ เอวมฺภนฺเตติ ขฺวาหํ ภิกฺขเว ธีตรญฺจ กุมารญฺจ พฺรหฺมทตฺตสฺส กาสิรญฺโญ ปฏิสฺสุณิตฺวา รถํ โยเชตฺวา พฺรหฺมทตฺตสฺส กาสิกสฺส ฉฑฺเฑตฺวา ยุตฺตา ขฺวาหํ เตเนว รเถน ยสฺสุธาธิ กาลํ มญฺญสีติ ฯ อถ ขฺวาหํ ภิกฺขเว พฺรหฺมทตฺตสฺส กาสิกสฺส รถํ อภิรุหิตฺวา ธีตรญฺจ กุมารญฺจ รถํ ปเวเสสิ ฯ ตถา ตถา รถํ ปเวเสสิ ยถา ยถา อญฺเญเนว เสนา อภิมาสิ อญฺเญเนว รเถน ฯ อถ ขฺวาหํ ภิกฺขเว พฺรหฺมทตฺตสฺส กาสิกสฺส ทูรํ คนฺตฺวา ธีตรญฺจ กุมารญฺจ ฉฑฺเฑตฺวา เตนหิ ภเณ

បង្គាប់ការអ្វី ។ ប្រពៃតែគួរជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ដល់ស្តេចកុដ្ឋកាសីព្រះនាមព្រហ្មទត្ត ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចកុដ្ឋកាសីព្រះនាមព្រហ្មទត្តមិនយូរប៉ុន្មានក៏ចាន់តាំងទីយាវុកុមារកុដ្ឋជាអគ្គសិទ្ធស្ថាលភាងកុដ្ឋ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចកុដ្ឋកាសីព្រះនាមព្រហ្មទត្តទ្រង់មានព្រះតម្រាស់នឹងទីយាវុកុមារយ៉ាងនេះថា នែនាយមាណព បើដូច្នោះចូរអ្នកទឹមពាជរថមក យើងនឹងទៅកាន់ទីប្រពាធម្ចឹគ ។ ម្នាលភិក្ខុទាំងឡាយ ឯទីយាវុកុមារទទួលស្តាប់ព្រះតម្រាស់ស្តេចកុដ្ឋកាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយក៏រៀបទឹមពាជរថរួចក្រាបទូលស្តេចកុដ្ឋកាសីព្រះនាមព្រហ្មទត្តយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាក្រោស ឯពាជរថរបស់ព្រះអង្គខ្ញុំព្រះអង្គទឹមរួចស្រេចហើយ សូមព្រះអង្គទ្រង់ជ្រាបកាលគួរឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចកុដ្ឋកាសីព្រះនាមព្រហ្មទត្តទ្រង់ឡើងគង់លើពាជរថ ទីយាវុកុមារក៏បររពាជរថទៅ ។ ពួកសេនាដើរទៅតាមផ្លូវឯទៀត ទីយាវុកុមារជាអ្នកបររពាជរថក៏បរទៅតាមផ្លូវឯទៀតបែករន្ធែរពីគ្នា ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចកុដ្ឋកាសីព្រះនាមព្រហ្មទត្តយាងទៅដល់ទីឆ្ងាយ ហើយទ្រង់មានព្រះតម្រាស់នឹងទីយាវុកុមារយ៉ាងនេះថា នែនាយមាណព បើដូច្នោះ

ឃាឃាវតា វជំ មុញ្ចិស្សុ តំលង្ការាបេត្វា ឆិបដ្ឋិស្សាមីតិ ។
ឯវំ ឧភតំ ខោ តំភក្ខវេ ទីឃាវុ កុមារោ [ព្រហ្មទត្តស្ស
កាសីរញ្ញោ បដិស្សុណិត្វា វជំ មុញ្ចិត្វា បហរិយំ បល្លង្ក-
ន ឆិសីទិ ។ អថខោ តំភក្ខវេ [ព្រហ្មទត្តោ កាសិរាជា
ទីឃាវុស្ស កុមារស្ស ឧច្ឆង្គេ សីសំ កត្វា សេយ្យំ
កប្បេសិ ។ តស្ស តំលង្កស្ស អុបាតុភោសេ ឆិន្នំ
ជីវិតេ ។ អថខោ តំភក្ខវេ ទីឃាវុស្ស កុមារស្ស ឯតទហោ-
សិ អយំ ខោ [ព្រហ្មទត្តោ កាសីរាជា តយាតោ អម្ហាកំ
អនត្ថស្ស ការការោ ឥមិនា អម្ហាកំ ពលញ្ច ឯហនញ្ច
ជនបទោ ច ខោសោ ច ខោជ្ជាការញ្ច អច្ចិន្នំ ឥមិនា
ច មេ មាតាបិតរោ ហតា អយំ ខ្វស្ស កាលោ យោហំ
វេរំ អប្បេយ្យន្តិ ខោសិយោ ខត្តំ ឆិញ្ជាហិ ។ អថខោ
តំភក្ខវេ ទីឃាវុស្ស កុមារស្ស ឯតទហោសិ បិតា ខោ មំ
មរណកាលេ អវច អា ខោ តំ តាត ទីឃាវុ ទីឃំ
បស្ស អា រស្សំ ន ហិ តាត ទីឃាវុ វេរេន វេរា សម្មន្តិ
អវេរេន ហិ តាត ទីឃាវុ វេរា សម្មន្តីតិ ន ខោ បេ
តំ បដិរូបំ យោហំ បិតុ វចនំ អតិក្កាមេយ្យន្តីតិ

ចូរអ្នកឯងដាក់ពរវេរសិន ដ្បិតយើងនឿយព្រួយលំបាក យើងនឹងដេក
សម្រាកបន្តិចសិន ។ ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារបានទទួល
ស្តាប់ព្រះតថាគតស្តេចកន្លងផុតនូវដែនកាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះ
គុណាវិសេស ហើយក៏ដាក់ពរវេរចេញអង្គុយពែនភ្នែនលើផែនដី ។ ម្នាល
ភិក្ខុទាំងឡាយ វេលានោះ ស្តេចកន្លងផុតនូវដែនកាសីព្រះនាមព្រហ្មទត្តក៏ទ្រង់
ផ្ទំកើយព្រះសីសៈលើភ្លៅទីឃាវុកុមារ ។ ស្តេចនោះនឿយព្រួយលំបាក
ទ្រង់ផ្ទំលក់មួយរំពេច ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ទីឃាវុកុមារ
ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ស្តេចកន្លងផុតនូវដែនកាសីព្រះនាមព្រហ្មទត្តនេះ
បានធ្វើសេចក្តីវិនាសជាច្រើនដល់អាត្មាអញ ទាំងពល ពាហនៈ ជនបទ
ឃ្លាំងទឹងជង្រែក របស់អាត្មាអញ ស្តេចនេះរឹបជាន់យកអស់ មិនតែ
ប៉ុណ្ណោះ ទាំងមាតាបិតារបស់អាត្មាអញ ស្តេចនេះក៏សម្លាប់ចោលអស់
វេលានេះ គួរអាត្មាអញសងពៀរដល់ស្តេចនេះវិញ ហើយក៏ហូតព្រះខាន់
ចេញពីស្រោម ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារមានសេច-
ក្តីត្រិះរិះយ៉ាងនេះថា បិតាបានផ្តាំអាត្មាអញក្នុងពេលដែលទៀបធ្វើមរណ-
ភាពថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុ
កូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯ
ពៀរតែងរម្ងាប់ដោយការមិនចងពៀរ បើអាត្មាអញកន្ទងពាក្យបិតាហើយ

โกสมฺพิยา ขนฺธกํ ปวารณา ฯ ทุติยมฺปิ ขฺวาหํ ภิกฺขเว ฯเปฯ ตติยมฺปิ ขฺวาหํ ภิกฺขเว ธมฺมวาทึ อธมฺมวาทึ ปฏิชานามิ อยมฺปิ ขฺวาหํ พฺรหฺมทตฺเต ราชา พหุกาโร อมฺหากํ อนุกมฺปโก ปาริจริยา ทายโก ปาโมชฺชกรณา ยาวญฺจิทํ จกฺขุมาปิ โสตวาปิ เจตสาปิ อภิปฺปสนฺโน จ เขตฺตาปิ จ เขตฺตปาลาปิ จ เมตฺตาปิ จ เม มาตาปิตโร ปาตา อยมฺปิ ขฺวสฺส ราชา ยาวหาหํ เวรา อเวรชฺฌตฺตา โกสมฺพิยา ขนฺธกํ นิฏฺฐาปิ ฯ ตติยมฺปิ ขฺวาหํ ภิกฺขเว ธมฺมวาทึ อธมฺมวาทึ ปฏิชานามิ ปิตา ขฺวาหํ มยฺหนฺติ อถ จ ปน ขฺวาหํ ตุมฺหากญฺเจว ตถาคตสฺส จ ธีตา ภคินี ปสฺส ยา วสฺสา น ปิ ตาต ธีตา เวเรน เวรา สมฺมนฺติ อเวเรน ปิ ตาต ธีตา เวรา สมฺมนฺตีติ น ขฺวาหํ เตน ปฏิวิโนเทมิ ยาวหาหํ ปิตุ วจนมฺ อตีกฺกเมยฺยนฺตีติ ปุนเทว โกสมฺพิยา ขนฺธกํ ปวารณา ฯ อถขฺวาหํ ภิกฺขเว พฺรหฺมทตฺเต ราชา กาลงฺกโต ทุพฺภิกฺขา ทุสฺสญฺญี ทุกฺกิสฺสา สหสา วุฏฺฐาสิ ฯ อถขฺวาหํ ภิกฺขเว

អំពើនេះឈ្មោះថាមិនសមគួរដល់អាត្មាអញទេឬយ ហើយក៏សៀតព្រះខាន់ទៅក្នុងស្រែរបស់អាត្មាអញវិញ ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារមានសេចក្តីត្រិះរិះជាគំរប់ពីរដងទៀត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារមានសេចក្តីត្រិះរិះជាគំរប់បីដងទៀតយ៉ាងនេះថា ស្តេចកងដែនកាសីព្រះនាមព្រហ្មទត្ត នេះបានធ្វើសេចក្តីវិនាសជាច្រើនដល់អាត្មាអញ ទាំងពល ពាហនៈ ជនបទ ឃ្លាំង ទឹងជង្រុករបស់អាត្មាអញ ស្តេចនេះរឹបជាន់យកអស់ មិនតែប៉ុណ្ណោះ ទាំងមាតាបិតារបស់អាត្មាអញ ស្តេចនេះក៏សម្លាប់ចោលអស់ វេលានេះ គួរអាត្មាអញសងឪពៃដល់ស្តេចនេះវិញ ហើយក៏ហូតព្រះខាន់ចេញពីស្រែ (ម្តងទៀត) ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារមានសេចក្តីត្រិះរិះជាគំរប់បីដងទៀតយ៉ាងនេះថា បិតាបានផ្តាំអាត្មាអញក្នុងពេលដែលទៀបធ្លុះមរណភាពថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៃរមិនដែលរម្ងាប់ដោយការចងពៃរទេ នែទីឃាវុកូន ឯពៃរតែងរម្ងាប់ដោយការមិនចងពៃរ បើអាត្មាអញកន្ធងពាក្យបិតាហើយ អំពើនេះឈ្មោះថាមិនសមគួរដល់អាត្មាអញទេឬយ ហើយក៏សៀតព្រះខាន់ទៅក្នុងស្រែរបស់អាត្មាអញវិញ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចកងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់កិតក័យភ្ញាក់ផ្អើលស្ងើតស្ងក់តក់ស្លុតហើយក៏តើនឡើងភ្លាម ។ ម្នាលភិក្ខុទាំងឡាយ

กោសម្ពិកក្ខន្ធកេ ទីឃាវុកុមារវត្ថុ

ទីឃាវុ កុមារោ ព្រហ្មទត្តំ កាសីរាជានំ ឯតទវោច កិំ ឃ្ញ
ត្វំ នេវ កីតោ ឧព្ពិក្តោ ឧស្សន្តិ ឧត្រស្តោ សមាសា
វុដ្ឋាសីតិ ។ ឥធ មំ ភណោ មាណវក ទីឃីតិស្ស កោ
សលរញ្ញោ បុត្តោ ទីឃាវុ កុមារោ សុបិនន្តេន ខត្តេ
បរិចារកេសិ តេនាហំ កីតោ ឧព្ពិក្តោ ឧស្សន្តិ ឧត្រស្តោ
សមាសា វុដ្ឋាសិន្តិ ។ អថខោ កិក្ខវេ ទីឃាវុ កុមារោ
ភាគិនេយ្យោ ព្រហ្មទត្តស្ស កាសីរញ្ញោ សីសំ
បរាមសិត្វា ឧក្កិណោន បាតេន ខក្កំ ឯញ្ជាបេត្វា
ព្រហ្មទត្តំ កាសីរាជានំ ឯតទវោច អហំ ខោ សោ នេវ
ទីឃីតិស្ស កោសលរញ្ញោ បុត្តោ ទីឃាវុ កុមារោ
ឥមាយោ ត្វំ អម្ហាកំ អនត្តស្ស ការកោ តយា អម្ហាកំ
ឥលញ្ញំ ឥមាឧញ្ញំ ឯនមនោ ច កោសោ ច កោដ្ឋា-
គារញ្ញំ អច្ឆិន្នំ តយា ច មេ មាតាបិតរោ ហតា អយំ
ខ្វស្ស ការោ យោហំ វោ អបេយ្យន្តិ ។ អថខោ កិក្ខវេ
ព្រហ្មទត្តោ កាសីរាជា ទីឃាវុស្ស កុមារស្ស ចាឧរង្គិ
សំវរសា ឯបតិត្វា ទីឃាវុំ កុមារំ ឯតទវោច ជីវិតំ មេ

កោសម្ពិកុក្កុរ: រឿងទីឃាវុកុមារ

ខណៈនោះ ទីឃាវុកុមារទូលសួរស្តេចកងដែនកាសីព្រះនាមព្រហ្មទត្ត យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ហេតុអ្វីបានជាព្រះអង្គទ្រង់កិតក័យភ្ញាក់ផ្អើលស្ងើតស្ងក់តក់ស្លុតហើយតើនឡើងភ្លាម ។ ស្តេចនោះតបវិញថា នែនាយមាណព ព្រោះយើងយល់សប្តិ (ថាដូចជា) ទីឃាវុកុមារជាកូនស្តេចកងដែនកោសលឈ្មោះទីឃីតិ លើកព្រះខាន់ឡើងគ្រាមយើងក្នុងទីនេះ ព្រោះហេតុនោះបានជាយើងកិតក័យភ្ញាក់ផ្អើលស្ងើតស្ងក់តក់ស្លុតហើយក្រោកឡើងភ្លាម ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ទីឃាវុកុមារយកដៃខាងឆ្វេងចាប់សង្កត់ព្រះសីស:ស្តេចកងដែនកាសីព្រះនាមព្រហ្មទត្ត ហើយយកដៃខាងស្តាំហូតព្រះខាន់រួចនិយាយពាក្យនេះទទឹងស្តេចកងដែនកាសីព្រះនាមព្រហ្មទត្តថា នែព្រះអង្គខ្លួនខ្ញុំឯងហើយដែលឈ្មោះទីឃាវុកុមារជាកូនស្តេចកងដែនកោសលព្រះនាមទីឃីតិ ព្រះអង្គបានធ្វើសេចក្តីវិនាសជាច្រើនដល់ខ្ញុំ ទាំងពលពាហន: ជនបទ ឃ្យាំង ទឹងដង្ក្រែករបស់ខ្ញុំ ព្រះអង្គក៏របជាន់យកអស់ មួយទៀត ទាំងមាតាបិតារបស់ខ្ញុំ ព្រះអង្គក៏សម្លាប់ចោលអស់ វេលានេះ គួរខ្ញុំសងតៀរដល់ព្រះអង្គវិញ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចកងដែនកាសីព្រះនាមព្រហ្មទត្តក៏ទូនព្រះសីរ្សក្រាបទៀបជើងទីឃាវុកុមារ ហើយមានព្រះរាជឱង្ការទទឹងទីឃាវុកុមារ

ตาต ธีตา นตฺถิ มม ตาต ธีตา นตฺถิ ฯ กฺยาหํ อุสฺสหามิ เทวสฺส ชีวิตา โรปนาย เทว มม ชีวิตา วโรปยาติ ฯ ตตฺถ ตาต ธีตา ตฺวญฺเว มม ชีวิตา วโรปยาติ อหเมว ตาต ธีตา ตฺวญฺเว มม ชีวิตา โรปยามิ ฯ อถ โข ตกฺกวี พฺรหฺมทตฺโต จ กาสีราชา ธีตา จ กุมาริ อญฺ-ญมญฺญสฺส ชีวิตา อโรเปสุ ตาณิญฺจ อกฺกเมสุ สปเทญฺจ อกาสุ อนฺตรธายถ[1] ฯ อถ โข ตกฺกวี พฺรหฺมทตฺโต กาสีราชา ธีตรญฺจ กุมารึ ปโรธญฺจ ตตฺถ ตาต ธีตรญฺจ รถญฺจ ยาเจหิ ตมิสฺสาเมติ ฯ ปฺวาหนฺติ โข ตกฺกวี ธีตรญฺจ กุมาริ พฺรหฺมทตฺตสฺส กาสีรญฺโญ ป-ฏิสฺสุณิตฺวา รถญฺจ ยาเจตฺวา พฺรหฺมทตฺตญฺ กาสีราชานญ ปโรธ-ญฺจ ยุตฺตา โข ตา ตตฺถ เทว ราช ยสฺสทานิ กาลญ มญฺญสีติ ฯ อถ โข ตกฺกวี พฺรหฺมทตฺโต กาสีราชา รถญ อภิรุหิ ธีตรญฺจ กุมาริ รถญ ปเวเสสิ ฯ ตถา ตถา รถญ ปเวเสสิ ยถา ยถา ธนิรสฺส สรายน

---

๑ ฉ. อโรกายน ฯ

យ៉ាងនេះថា នែទីយាវុកូន សូមអ្នកអាណិតឲ្យជីវិតដល់យើងផង នែទីយាវុកូន សូមអ្នកអាណិតឲ្យជីវិតដល់យើងផង ។ ទីយាវុកុមារតបវិញថា ខ្ញុំនឹងអាចផ្សាយជីវិតព្រះអង្គដូចម្តេចបាន គួរតែព្រះអង្គប្រទានជីវិតមកខ្ញុំវិញ ។ ស្តេចនោះទ្រង់ត្រាស់ថា នែទីយាវុកូន បើដូច្នោះអ្នកឯងចូរឲ្យជីវិតដល់យើងចុះ យើងក៏ឲ្យជីវិតដល់អ្នកឯងវិញ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះស្តេចកុងវែនកាសីព្រះនាមព្រហ្មទត្តនឹងទីយាវុកុមារបានឲ្យជីវិតគ្នាទៅវិញទៅមក ហើយបានទាំងចាប់ដៃគ្នាផងធ្វើសម្បថផង ដើម្បីមិនឲ្យមានរឿងប្រទូស្តគ្នាគ្នាទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចកុងវែនកាសីព្រះនាមព្រហ្មទត្តទ្រង់មានព្រះទុក្ខារទៅនឹងទីយាវុកុមារយ៉ាងនេះថា នែទីយាវុកូន បើដូច្នោះចូរអ្នកទឹមរាជរថចុះ យើងនឹងត្រឡប់ទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ ឯទីយាវុកុមារបានទទួលស្តាប់ព្រះទុក្ខារស្តេចកុងវែនកាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយក៏ទឹមរាជរថរួចក្រាបទូលស្តេចកុងវែនកាសីព្រះនាមព្រហ្មទត្តយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាក្រោស ឯរាជរថរបស់ព្រះអង្គខ្ញុំព្រះអង្គទឹមរួចស្រេចហើយ សូមព្រះអង្គទ្រង់ជ្រាបកាលគួរឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ ខណៈនោះ ស្តេចកុងវែនកាសីព្រះនាមព្រហ្មទត្តទ្រង់យាងឡើងគង់លើរាជរថ ឯទីយាវុកុមារក៏បររាជរថទៅ ។ មិនយូរប៉ុន្មានទីយាវុកុមារក៏បររាជរថទៅ

កោសម្ពិកក្ខន្ធកេ ទុយ្យោកុមារវត្ថុ

សមាកច្ចំ ។ អថខោ កិកិវេ ព្រហ្មទត្តោ កាសីរាជា
ពារាណសិំ បវិសិត្វា អមច្ចេ ចារិសេ្ស សន្ធិចាតាបេត្វា
ឯតទវោច សចេ កណោ ទីឃីតិស្ស កោសលរញ្ញោ
បុត្តំ ទីឃាវុំ កុមារំ បសេ្សយ្យាថ កិន្តិ តំ ករេយ្យា-
ថាតិ ។ ឯកច្ចេ អមច្ចា ឯវមាហំសុ មយំ ទេវ ហាត្ថេ
ឆិន្ទេយ្យាម មយំ ទេវ ទាទេ ឆិន្ទេយ្យាម មយំ ទេវ
ហត្ថទាទេ ឆិន្ទេយ្យាម មយំ ទេវ កណ្ណេ ឆិន្ទេយ្យាម
មយំ ទេវ នាសំ ឆិន្ទេយ្យាម មយំ ទេវ កណ្ណនាសំ
ឆិន្ទេយ្យាម មយំ ទេវ សីសំ ឆិន្ទេយ្យាមាតិ ។ អយំ ខោ
សោ កណោ ទីឃីតិស្ស កោសលរញ្ញោ បុត្តោ ទីឃាវុ
កុមារោ នាយំ លព្ភា កិញ្ចិ កាតុំ ឥមិនា ច មេ ជីវិតំ
ឆឌ្ឌំ មយោ ច ឥមស្ស ជីវិតំ ទិន្នន្តិ ។ អថខោ កិកិវេ

ដួចនឹងពួកសេនាដែលទៅតាមផ្លូវផ្សេងពីគ្នានោះ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចកងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់យាងចូលទៅក្រុងពារាណសីហើយទ្រង់ប្រជុំពួក អមាត្យជាឋានសន្សួចហើយទ្រង់មានព្រះឱង្ការយ៉ាងនេះថា នែនាយ ប្រសិនបើអ្នកទាំងឡាយបានឃើញទីឃាវុកុមារជាកូនស្តេចកងដែនកោសលឈ្មោះទីឃីតិហើយ តើគួរធ្វើទីឃាវុកុមារនោះដូចម្តេច ។ អមាត្យទាំងឡាយក៏ក្រាបទូលដោយពួក ។ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ដៃចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ដើងចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ទាំងដៃទាំងដើងចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ត្រចៀកចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ច្រមុះចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ទាំងត្រចៀកទាំងច្រមុះចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ក្បាលចេញ ។ ស្តេចនោះទ្រង់ត្រាប់ថា នែនាយទាំងឡាយ បុរសនេះឯងហើយដែលឈ្មោះទីឃាវុកុមារជាកូនស្តេចកងដែនកោសលឈ្មោះទីឃីតិនោះ អ្នកទាំងឡាយមិនត្រូវធ្វើទោសកុមារនេះតបតួបទេ ព្រោះកុមារនេះបានឲ្យជីវិតយើង យើងក៏បានឲ្យជីវិតដល់កុមារនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ

[๑๒๗] เตน โข ปน สมเยน ราชา มาคโธ เสนิโย พิมฺพิสาโร
เตส ตาส เนว ปุตฺโต อโหสิ น ธีตา ตสฺส ราชิโน เสนิยสฺส
พิมฺพิสารสฺส ปุตฺตกามสฺส ปุตฺตปฏิลาภาย ปุตฺตมุขทสฺสนาย
ปุตฺตปริโภคาย ปุตฺตสฺส ชาตกมฺมานิ กาเรสิ ปุตฺตสฺส นามกรณานิ
กาเรสิ ปุตฺตสฺส จูฬกรณานิ กาเรสิ ปุตฺตสฺส ปชาปตึ อานยิ
ปุตฺตสฺส ปาทาวนานิ กาเรสิ ปุตฺตสฺส ปาทาวนมงฺคลานิ กาเรสิ
ปุตฺตสฺส ปาทาวนมงฺคลานิ กาเรสิ ปุตฺตสฺส ปาทาวนมงฺคลานิ
กาเรสิ

ស្តេចកន្លងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់មានព្រះឧង្ការទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែទីឃាវុកូន កាលដែលបិតារបស់អ្នកជិតនឹងធ្វើមរណកាតបានផ្តាំបណ្តាំណាចំពោះអ្នកឯងថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ តើបិតារបស់អ្នកសំដៅយកហេតុត្រង់ណា បានជាផ្តាំ (ដូច្នេះ) ។ ទីឃាវុកុមារក្រាបទូលថា សូមទ្រង់ព្រះមេត្តាជ្រាស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណកាតបានផ្តាំបណ្តាំណាចំពោះខ្ញុំព្រះអង្គថា អ្នកកុំឃើញកាលវែង គឺថាអ្នកឯងកុំធ្វើពៀរឲ្យយូរអង្វែងឡើយ សូមទ្រង់ព្រះមេត្តាជ្រាស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណកាតបានផ្តាំបណ្តាំនេះឯង (នេះហៅថា) កុំឃើញកាលវែង សូមទ្រង់ព្រះមេត្តាជ្រាស កាលដែលបិតារបស់ខ្ញុំព្រះអង្គទៀបនឹងធ្វើមរណកាតបានផ្តាំបណ្តាំណាចំពោះខ្ញុំព្រះអង្គថា អ្នកឯងកុំឃើញកាលខ្លី គឺថាអ្នកឯងកុំប្រញាប់ប្រែកចាកពួកមិត្តសំឡាញ់ឡើយ សូមទ្រង់ព្រះមេត្តាជ្រាស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណកាតបានផ្តាំបណ្តាំនេះឯង (នេះហៅថា) កុំឃើញកាលខ្លី សូមទ្រង់ព្រះមេត្តាជ្រាស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណកាតបានផ្តាំបណ្តាំណាចំពោះខ្ញុំព្រះអង្គថា នែទីឃាវុកូន ធម្មតាពៀរ

សម្មន្តិ អវៅវេន មា តាត ទីឃាវុ វៅ សម្មន្តីតំ នេវេន មេ មាតាបិតវោ ហាតាតំ សចាហំ នេវំ ជីវិតា ភៅវោ បេយ្យំ យេ នេវស្ស អត្តកាមា តេ មំ ជីវិតា ភៅវោ បេយ្យុំ យេ មេ អត្តកាមា តេ តេ ជីវិតា ភៅវោបេយ្យុំ ឃវន្តំ វៅំ វៅវេន ន រូបសមេយ្យ ឥតាដំ ច បន មេ នេវេន ជីវិតំ និន្តំ បយា ច នេវស្ស ជីវិតំ និន្តំ ឃវន្តំ(๑) វៅំ អវៅវេន រូបសន្តំ ឥមំ ខោ មេ នេវ បិតា មរណាកាសេ អវច ន មា តាត ទីឃាវុ វៅវេន វៅ សម្មន្តិ អវៅវេន មា តាត ទីឃាវុ វៅ សម្មន្តីតំ ។ អថខោ តំក្ខណេ ព្រហ្មទត្តោ ការាសីរាជា អច្ចរិយំ វត ភោ អព្ភុតំ វត ភោ យាវ បណ្ឌិតោ អយំ ទីឃាវុ កុមារោ យ្រអំ ហិ នាម បិតុនោ សន្តិកេន ការិតស្ស វិត្ថារេន អត្តំ អាជានិស្សតីតំ បេតិកំ ពលញ្ច ឣាមាធញ្ច ជនបទញ្ច ភោសញ្ច

๑ ម.ឯវំ ។

មិនដែលរម្ងាប់ដោយការចង់ពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចង់ពៀរ (នោះសំដៅត្រង់) មាតាបិតារបស់ខ្ញុំព្រះអង្គដែលព្រះអង្គសម្លាប់ចោលអស់ ព្រោះហេតុនោះ បើខ្ញុំព្រះអង្គនឹងបំផ្លាញព្រះអង្គឲ្យដាច់ចាកជីវិតហើយ គង់មានពួកជនដែលប្រាថ្នាប្រយោជន៍ចំពោះព្រះអង្គនឹងបំផ្លាញខ្ញុំព្រះអង្គឲ្យដាច់ចាកជីវិតវិញ ពួកជនដែលប្រាថ្នាប្រយោជន៍ដល់ខ្ញុំព្រះអង្គ មុខជានឹងបំផ្លាញជនទាំងនោះឲ្យដាច់ចាកជីវិតមិនខាន ឬ្យ ពៀរនោះមិនបានរម្ងាប់ដោយការចង់ពៀរយ៉ាងនេះឯង ឥឡូវព្រះអង្គទ្រង់ប្រទានជីវិតដល់ខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គក៏ថ្វាយជីវិតដល់ព្រះអង្គវិញ ពៀរនោះនឹងរម្ងាប់ដោយការមិនចង់ពៀរយ៉ាងនេះឯង សូមទ្រង់ព្រះមេត្តាត្រាស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណភាពបានផ្តាំបណ្តាំនេះឯងថា នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចង់ពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចង់ពៀរ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចកុងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់ស្ទើចថា អើហ្ន៎ (ហេតុនេះ) ហៅពេញជាអស្ចារ្យណាស់ អើហ្ន៎ (ហេតុនេះ) ហៅពេញជាចំឡែកណាស់ ទីឃាវុកុមារនេះពេញជាអ្នកប្រាជ្ញមែន ព្រោះដំណឹងសេចក្តីដែលបិតាពោលដោយសង្ខេប ដោយពិស្តារបាន ហើយក៏ទ្រង់ត្រឡប់ប្រគល់ពល ពាហនៈ ជនបទ ឃ្លាំង

กตฺวา ฐานาทีสุ ยถารหเมว อธิวาเสนฺโต ฯ ตสฺส ปน ภิกฺขุโน ปตฺตจีวรานิ อาทาย ปจฺฉา ปจฺฉา คจฺฉนฺตา ปาฏิยเมว ปาจิตฺติยาปตฺติยา กาเรตพฺพา ฯ ๙๓ ๑๐ ยถา ปน ภิกฺขุนา ปาฏิยเมว ปาจิตฺติยาปตฺติ เทสาเปตพฺพา ตถา ปาฏิเทสนียาปตฺติ ทุกฺกฏาปตฺติ ทุพฺภาสิตาปตฺติ สมานา ๑๐ ๑๐ ๑๐ ปาจิตฺติยาปตฺติยา เทสนา ปาฏิ ฯ

(๑๙๑) ตติยมฺปิ ๑๐ ภควา ตเมว ภิกฺขุ ปจฺจเวกฺขิ อลํ ภิกฺขุ ปา ภณฺฑนํ ปา กลหํ ปา วิคฺคหํ ปา วิวาทนฺติ ฯ ตติยมฺปิ ๑๐ เสา อฉมฺภตี ภิกฺขุ ภควนฺตเมว ปจฺจเวกฺขิ อาคเมตุ ภนฺเต ภควา ธมฺมสฺสามี อเปฺปสฺสุกฺโก ภนฺเต ภควา ติฏฺฐธมฺมสุขวิหารํ อนุยุตฺโต วิหรตุ

ន៏ដ្បែក ជាដំណែលបិតាទៅទីយោវុកុមារវិញ ឲ្យបានតាំងប្រគានធីតា ១ ថែមទៀត ។ ម្នាលភិក្ខុតាំងឡាយ គួរកោតដែរ យ៉ាងពួកក្សត្រតាំងនោះ (ឆ្ងាប់តែ) កាន់ដំបង (ឆ្ងាប់តែ) កាន់គ្រឿងសស្ត្រាហើយ បេះមានអំណាត់ន៏ងសេចក្តីប្រព្រឹត្តល្អបែបនេះបាន ។ ព្រោះហេតុដូច្នោះ ម្នាលភិក្ខុតាំងឡាយ អ្នកពាល់គ្នាបានមកបួសក្នុងធម្មវិន័យនេះដែលតថាគតបានសំដែងដោយល្អយ៉ាងនេះហើយ គួរតែខំអត់ធន់ គួរតែខំប្រព្រឹត្តល្អឲ្យល្អឡើង ។

(១៥១) ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកាទៅន៏ងភិក្ខុតាំងនោះជាគំរប់បីដងយ៉ាងនេះថា ម្នាលភិក្ខុតាំងឡាយ កុំឡើយ អ្នកតាំងឡាយកុំធ្វើសេចក្តីបង្កហេតុ កុំធ្វើសេចក្តីឈ្លោះគ្នា កុំធ្វើសេចក្តីប្រកាន់ផ្សេង ។ គ្នា កុំធ្វើសេចក្តីវិវាទគ្នាឡើយ ។ ឯអធម្មវាទីភិក្ខុនោះក្រាបបង្គំទូលព្រះដ៏មានព្រះភាគជាគំរប់បីដងយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគជាធម្មស្វាមីទ្រង់ឈប់បន្ទ៏ងចុះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគមានសេចក្តីខ្វល់ខ្វាយតិច សូមទ្រង់ប្រកបតែន៏ងធម៌ដែលជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នវិញ ។ ចុះ

មយមេតេន កល្លានេន កុសលេន បុញ្ញេន វាតេន
បញ្ញាយ សិស្សមាតិ ។ អថខោ ភគវា បរិយោទិន្នរូបា
ខោ ឥមេ មោឃបុរិសា ឆយិមេ សុតវា សញ្ញាមេតុន្តិ
ឧដ្ឋាយាសនា បក្កាមិ ។

ទីឃាវុភាណវារំ បឋមំ ។

[๑๔๒] អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា
បត្តចីវរមាទាយ តោសម្ពិំ បិណ្ឌាយ បាវិសិ តោសម្ពិយំ
បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ
សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ សង្ឃមជ្ឈំ
បិតោ តោ ឥមា គាថាយោ អភាសិ ។

ពោសម្ពីក្ខន្ធកៈ អំណាត់ធំងការប្រែព្រឹត្តិឆ្គួនធំងគាថាសំដែងអំពីការរាប់នូវពៀរ

ឯយើងខ្ញុំទាំងឡាយមុខជានឹងច្បាកដដោយសេចក្តីបង្អកហេតុ ដោយសេច-
ក្តីឈ្លោះគ្នា ដោយសេចក្តីប្រកាន់ផ្សេង ៗ គ្នា ដោយសេចក្តីវិវាទគ្នាមិន
ខាន ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់រំពិចារណាថា ពួកមោឃបុរស
ទាំងនេះមានសភាពគឺកិលេសគ្របសង្កត់ហើយ តថាគតមិនងាយនឹង
ពន្យល់មោឃបុរសទាំងនេះបានឡើយ ហើយក៏ទ្រង់គ្រោកចាកអាសនៈ
ចៀសចេញទៅ ។

ចប់ ភាណវារៈពោលអំពីទីឃាវុកុមារ ទី ១ ។

[១៥២] លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ហើយ
ទ្រង់ប្រដាប់ចីវរយាងចូលទៅក្រុងកោសម្ពីដើម្បីបិណ្ឌបាតក្នុងពេលព្រឹក
ត្រហាម លុះយាងទៅបិណ្ឌបាតក្នុងក្រុងកោសម្ពីហើយទ្រង់ត្រឡប់មកពី
បិណ្ឌបាតវិញ ក៏ទ្រង់រៀបទុកជាក់ត្រឿងសេនាសនៈ ហើយកាន់យក
ប្រដាប់ចីវរ ទ្រង់ឋិតកណ្តាលដំទុំសង្ឃ ក្នុងវេលាត្រៀយកគ្គ ហើយ
ទ្រង់ពោលព្រះគាថាទាំងនេះថា

(๑๔๓) ปุถุสทฺโท สมชฺชโต.

น ตาโว เถาจิ มญฺเญ

สงฺฆสฺมึ ภิชฺชมานสฺมึ

ตาวญฺหิ ภิยฺโย อปญฺโญ ฯ

ปริมุฏฺโ ปณฺฑิตาภาสา

ยาวาเถาจรภาณิเต

เยวิจฺฉกฺขิ มุขายามึ

เยน นีตา น ตึ วิทู

อเถกจฺเจ มหิ มึ

อณิเก มึ อหาสึ เม

เย จ ตึ อุปนยฺหนฺติ

เวรึ เตสึ น สมฺมติ ฯ

อเถกจฺเจ มึ มหิ มึ

อณิเก มึ อหาสึ เม

เย จ ตึ อุปนยฺหนฺติ

เวรึ เตสูปสมฺมติ ฯ

น หิ เวเรน เวรานิ

(១៥៣) ជននេះមានសំឡេងខ្ចាំងផង ជាជនប្រហែលគ្នាផង សូម្បីជនណាមួយដឹងខ្លួនថាជាបុគ្គលពាលក៏គ្មាន កាលបើសង្ឃកំពុងតែបែកគ្នា ជនទាំងឡាយក៏មិនបានដឹងហេតុដទៃឲ្យក្រៃលែង ។ ពួកជនដែលភ្លេចស្មារតី ហើយធ្វើបុគ្គ-ញ្ញខ្លួនដូចជាអ្នកជ្រាជ្ញ មានសំដីជាអារម្មណ៍ ចង់ហាមាត់និយាយប៉ុន្មាន ក៏និយាយប៉ុណ្ណោះទៅ ទុកជាមានគេនាំទៅប្រដៅឲ្យឈ្លោះគ្នា ក៏មិនដឹងសេចក្តីនោះថាជាសេចក្តីឈ្លោះឡើយ ។ ពួកជនណាចង់សេចក្តីក្រោធនោះទុកដោយគិតថា ជនឯណោះបានដេរអាត្មាអញ ជនឯណោះបានវាយអាត្មាអញ ជនឯណោះបានផ្តាច់ផ្តួលអាត្មាអញ ជនឯណោះបានលួចទ្រព្យអាត្មាអញ ពៀរបស់ជនទាំងនោះមិនបានរម្ងាប់ទេ ។ ម្យ៉ាងទៀត ពួកជនណាមិនបានចង់សេចក្តីក្រោធនោះទុកដោយគិតថា ជនឯណោះបានដេរអាត្មាអញ ជនឯណោះបានវាយអាត្មាអញ ជនឯណោះបានផ្តាច់ផ្តួលអាត្មាអញ ជនឯណោះបានលួចទ្រព្យអាត្មាអញ ពៀរបស់ជនទាំងនោះទើបរម្ងាប់ទៅបាន ។ ក្នុងលោកនេះ ធម្មតាពៀរ

ភោសម្ពីភ្នុកេ វេរុបសមគាថា

សម្មទ្ធិឆ ភុធាចរំ
អវៃរេន ច សម្ពុទ្ធិ
ឱស ឆម្ពោ សរេន្តោ ។
បវេ ច ន វិជាឆន្តិ
មយៃមេត្ត យមាម្ហសេ
យេ ច តត្ត វិជាឆន្តិ
តតោ សម្មទ្ធិ មេឆតា ។
អដ្ឋិដ្ឋិន្ទា[1] ចាណហាក
តភាសុរេនមហារិនោ
វដ្ដំ វិលុម្បមានានំ
តេសំបិ ហោតិ សង្គតិ ។
ភាស្ហា ភុម្ហាភ ឆោ សរិយោ ។
សចេ លភេថ ឆិមភាំ សហាយំ
សទ្ធិញ្ចរំ សាធុវិហារទីរំ

---

๑ ឧ. អដ្ឋដ្ឋិន្ទា ។

មិនដែលរម្ងាប់ទៅដោយការចងពៀរបានម្ដងឡើយ រម្ងាប់បានតែដោយការបំនងចងពៀរ នេះជាធម្មតាតែងមានពីដើមរៀងមក ។ ពួកជនដទៃមិនដែលដឹងច្បាស់ថា យើងដល់នូវសេចក្ដីវិនាសក្នុងកណ្ដាលដំទុំសង្ឃនេះទេ បណ្ដាជនទាំងនោះ បើពួកជនណាមួយដឹងច្បាស់ សេចក្ដីឈ្លោះទើបរម្ងាប់អំពីសំណាក់ជនទាំងនោះបាន ។ អម្បាលឆ្នូដ៏មាតាបិតារបស់ទីឃាវុកុមារគេកាត់ចោល ទាំងជីវិតគេក៏សម្ងាប់ចោល ទាំងគោ សេះ ទឹងជនជានគេក៏នាំយកទៅ ទាំងដែនគេក៏រឹបជាន់ដណ្ដើមយកអស់ ម្ដេចស្ដេចទាំងនោះគង់ទៅមានសេចក្ដីព្រមព្រៀងគ្នាបាន ។ ចុះអ្នកទាំងឡាយហេតុអ្វីក៏គ្មានសេចក្ដីព្រមព្រៀងគ្នា ។

បើបុគ្គលបានសំឡាញ់មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន[1] ជាអ្នកប្រាជ្ញមានធម៌ជាគ្រឿងទៅសប្បាយ គ្រាចរទៅជាមួយគ្នា

---

១ ក្នុងអដ្ឋកថា មេត្តសូត្តថា បុគ្គលមានប្រាជ្ញា បេះរក្សាសីលឲ្យបរិសុទ្ធនឹងពិចារណាបច្ច័យមានបីវិរជាដើម នឹងកំណត់ដឹងនូវសេចក្ដីសប្បាយ ៣យ៉ាង មានសេប្បាយដោយអាវាសជាដើម ហៅថា មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ។

អភិក្កុយ្យ សព្ពានិ បរិស្សយានិ

ចរេយ្យ តេនត្តមនោ សតីមា ។

នោ ចេ លភេថ និបកំ សហាយំ

សទ្ធិញ្ចរំ សាធុវិហារិធីរំ

ភជាវ រដ្ឋំ វិជិតំ បហាយ

ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

ឯកស្ស បរិតំ សេយ្យោ

នត្ថិ ពាលេ សហាយតា ។

ឯកោ ចរេ ន ច បាបានិ កយិរា

អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោតិ ។

បុគ្គលនោះ អាចគ្រែបសង្កត់នូវសេចក្តីអន្តរាយទាំងពួងបាន ហើយជាអ្នកមានសេចក្តីត្រេកអរមានស្មារតី គប្បីត្រាច់ទៅជាមួយនឹងសំឡាញ់នោះចុះ ។ បើបុគ្គលមិនបានសំឡាញ់ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងទៅសប្បាយ ត្រាច់ទៅជាមួយគ្នាទេ បុគ្គលនោះគួរត្រាច់ទៅតែម្នាក់ឯង ប្រៀបដូចជាស្តេចសរបង់ដែនដែលខ្លួនឈ្នះហើយត្រាច់ទៅម្នាក់ឯង (ពុំនោះសោត) ប្រៀបដូចជាដំរីដ៏ប្រសើរត្រាច់ទៅម្នាក់ឯងក្នុងព្រៃ ។ ការដែលបុគ្គលត្រាច់ទៅតែម្នាក់ឯង ហៅពេញជាប្រសើរ ព្រោះបុគ្គលពាលគ្មានសហាយតាគុណ(១)ទេ ។ ម្យ៉ាងទៀត បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង មិនគួរធ្វើអំពើលាមកឡើយ ប្រៀបដូចជាដំរីដ៏ប្រសើរមានសេចក្តីខ្ពើមខ្លាយតិច ត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ ។

---

១ អដ្ឋកថាធម្មបទថា បុល្លសីល មដ្ឋិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ អមតមហានិព្វាន ហៅថា សហាយ-តាគុណ ។

(๑๙๔) អថខោ ภคภา สงฺฆมชฺเฌ นิสินฺโน ภิกฺขู อามนฺเตสิ ภิกฺขโว ภาสิตฺถา เยน ฌาลกเลาณาการคาโม[๑] เตนุปสงฺกมิ ฯ เตน ขោ បន สมเยน อายสฺมา ภคุ ฌาลกเลาณาการคาเม วิหรติ ฯ อถ ขោ อายสฺมา ภคุ ภคฺคេ ทูรเต ว อาคจฺฉนฺติ ทิสฺวาน อาสนំ បញฺญเปสิ ปาโททกំ ปาทปีឋំ ปา-ทกถលิกំ ឧปนิกฺขิปิ បច្ចุคฺคนฺตฺวา បត្តចีวรំ បដิคฺคเหสิ ฯ นิสีทิ ภคภา បញฺญตฺเต อาสเน นิสชฺช ปาเท បក្ខาเลสิ ฯ อายสฺมាបិ ขោ ภคุ ภคฺคินฺโท อภิวา-เทตฺวา เอกมนฺตំ นิสีทิ ฯ เอกมนฺตំ นิสินฺโน ขោ อายสฺมนฺตំ ภคุំ ภគภา เอតទเวจ ภาสิ កិត្តក ខោ-นីយំ ภាสิ យាបនីយំ ภាสิ បิณฺฑาโกล ฉ ភិលา-បសីតិ ฯ ខោนីយំ ภគภ យាបនីយំ ภគภ ฉ ปาหំ ภនฺเต បិណฺฑาโกล ភិលาបามីតិ ฯ អថខោ ภគภ อายสฺมนฺตំ

---

๑ ฉ. ฌาลกเลาณาการาเมา ฯ

(១៥៤) កាលបើព្រះមានព្រះភាគទ្រង់ឋិតកណ្តាលដំនុំសង្ឃ ពោលព្រះគាថាអម្បាលនេះហើយ ក៏ទ្រង់យាងទៅឯពាលកលោណការកគ្រាម ។ សម័យនោះឯង ក៏ចួនជាព្រះភគុដ៏មានអាយុគង់នៅក្នុងពាលកលោណការកគ្រាមដែរ ។ ឯព្រះភគុដ៏មានអាយុបានឃើញព្រះមានព្រះភាគទ្រង់យាងមកអំពីចម្ងាយ លុះឃើញហើយក៏រៀបក្រាលអាសនៈរួចដំកល់ទឹកសម្រាប់លាងព្រះបាទ តាំងសម្រាប់ទ្រព្រះបាទដែលលាងរួចហើយនឹងគ្រឿងសម្រាប់ទ្រព្រះបាទដែលមិនទាន់លាង ស្រេចហើយទើបក្រាកឡើងទៅទទួលបាតនឹងចីវរ ។ ព្រះមានព្រះភាគក៏ទ្រង់គង់លើអាសនៈដែលកិក្ខុក្រាលថ្វាយ លុះគង់ហើយទើបលាងព្រះបាទ ។ ចំណែកឯព្រះភគុដ៏មានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគរួចអង្គុយនៅក្នុងទីសមគួរ ។ លុះព្រះភគុដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុ អ្នកល្មមអត់ធន់បានទេឬ អ្នកល្មមប្រព្រឹត្តទៅបានស្រួលទេឬ អ្នកមិនលំបាកដោយបិណ្ឌបាតទេឬ ។ ព្រះភគុដ៏មានអាយុក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គល្មមអត់ធន់បាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គល្មមប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស ម្យ៉ាងទៀត ខ្ញុំព្រះអង្គមិនលំបាកដោយបិណ្ឌបាតទេ ។ លំនោះ ព្រះមានព្រះភាគ

กกุธ ภนฺเตยฺโย กถาย สนฺตสฺเสตฺวา สมาธเปตฺวา สมุตฺเต-
เชตฺวา สมฺปหํเสตฺวา ธมฺมิยา สนฺถาย เยน ถาปิตวิสา-
ขาโย เตนุปสงฺกมิ ฯ เตน โข ปน สมเยน
อายสฺมา จ อนุรุทฺโธ อายสฺมา จ นนฺทิโย อายสฺมา จ
กิมฺพิโล ถาปิตวิสขาเย วิหรนฺติ ฯ อทฺทสา โข ขาย-
ถาลโก ภควนฺตํ ทูรโตว ฯ อาคจฺฉนฺตํ ทิสฺวาน ภควนฺตํ
เอตทโวจ มา สมณา เอตํ ขาทิ มา เตสํ อชา-
สุมกาสีติ ฯ อสฺโสสิ โข อายสฺมา อนุรุทฺโธ
ขาทิถาลสฺส ภควโต สทฺทึ มนฺตยมานสฺส สุตฺวาน
ขาทิถาลกสฺส เอตทโวจ มา อาวุโส ขาทิถาลก
ภควนฺตํ ปาเรสิ สตฺถา โลเก ภควา อนุญฺญาตีติ ฯ
อถ โข อายสฺมา อนุรุทฺโธ เยนายสฺมา จ นนฺทิโย
อายสฺมา จ กิมฺพิโล เตนุปสงฺกมิ อุปสงฺกมิตฺวา
อายสฺมนฺตญฺจ นนฺทิยํ อายสฺมนฺตญฺจ กิมฺพิลํ เอตทโวจ

ទ្រង់ពន្យល់ព្រះគុណដ៏មានអាយុឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈយាងទៅឯប្រទេសនៃព្រៃឈ្មោះបាចីនវង្ស ។ សម័យនោះឯង ចួនជាព្រះអនុរុទ្ធដ៏មានអាយុ ១ ព្រះនន្ទិយៈដ៏មានអាយុ ១ ព្រះកិម្ពិលៈដ៏មានអាយុ ១ គង់នៅក្នុងប្រទេសនៃព្រៃឈ្មោះបាចីនវង្សដែរ ។ មានបុរសម្នាក់ជាអ្នករក្សាព្រៃ បានឃើញព្រះមានព្រះភាគទ្រង់យាងមកអំពីចម្ងាយ លុះឃើញហើយក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះសមណៈ ព្រះអង្គកុំយាងចូលទៅក្នុងព្រៃនេះឡើយ ដ្បិតមានពួកកុលបុត្ត ៣ រូប មានសភាពជាអ្នកស្រឡាញ់ខ្លួននៅក្នុងព្រៃនេះ ព្រះអង្គកុំធ្វើសេចក្តីអផ្សុកដល់កុលបុត្តទាំងនោះឡើយ ។ ព្រះអនុរុទ្ធដ៏មានអាយុក៏បានឮពាក្យបុរសជាអ្នករក្សាព្រៃ កំពុងប្រកាសជាមួយនឹងព្រះមានព្រះភាគដែរ លុះឮហើយក៏និយាយទៅនឹងបុរសជាអ្នករក្សាព្រៃយ៉ាងនេះថា ម្នាលអ្នករក្សាព្រៃដ៏មានអាយុ អ្នកឯងកុំឃាត់ព្រះមានព្រះភាគឡើយ ដ្បិតព្រះមានព្រះភាគជាគ្រូរបស់យើងទ្រង់យាងមកដល់ហើយ ។ ខណៈនោះ ព្រះអនុរុទ្ធដ៏មានអាយុចូលទៅរកព្រះនន្ទិយៈដ៏មានអាយុ នឹងព្រះកិម្ពិលៈដ៏មានអាយុ លុះចូលទៅដល់ហើយក៏និយាយនឹងព្រះនន្ទិយៈដ៏មានអាយុនឹងព្រះកិម្ពិលៈ

អភិក្កមថាយស្មន្តោ អភិក្កមថាយស្មន្តោ សត្ថា ខោ
ភគវា អនុបុព្ពត្តោតិ ។ អថខោ អាយស្មា ច អនុរុទ្ធោ
អាយស្មា ច នន្ទិយោ អាយស្មា ច កិម្ពិលោ ភគវន្តំ
បច្ចុគ្គន្ត្វា ឯកោ ភគវតោ បត្តចីវរំ បដិគ្គហេសិ ឯកោ
អាសនំ បញ្ញាបេសិ ឯកោ ចាតោទកំ ចានបីឋំ ចាន-
កថលិកំ ឧបនិក្ខិបិ ។ និសីទិ ភគវា បញ្ញត្តេ
អាសនេ និសជ្ជ ចាតេ បក្ខាលេសិ ។ តេ បិ ខោ
អាយស្មន្តោ[1] ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។
ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អនុរុទ្ធំ ភគវា ឯត-
ទវោច កច្ចិ ភោ អនុរុទ្ធា ខមនីយំ កច្ចិ យាបនីយំ

---

๑ ម. អាយស្មន្តោ ។

ជ័មានអាយុយ៉ាងនេះថា ម្នាលលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំងឡាយនិមន្តទៅទទួល ម្នាលលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំងឡាយនិមន្តទៅទទួល ដ្បិតព្រះមានព្រះភាគជាគ្រូរបស់យើង ព្រះអង្គទ្រង់យាងមកដល់ហើយ ។ លំដាប់នោះ ព្រះអនុរុទ្ធដ៏មានអាយុ ព្រះនន្ទិយៈដ៏មានអាយុ និងព្រះកិម្ពិលៈដ៏មានអាយុ ក៏ក្រោកទៅទទួលព្រះមានព្រះភាគ មួយអង្គទទួលបាត្រនិងចីវរព្រះមានព្រះភាគ មួយអង្គរៀបចំក្រាលអាសនៈ មួយអង្គដំកល់ទឹកសម្រាប់លាងព្រះបាទ តាំងសម្រាប់ដំកល់ព្រះបាទដែលលាងហើយ និងគ្រឿងសម្រាប់ដំកល់ព្រះបាទដែលមិនទាន់បានលាង ។ ព្រះមានព្រះភាគទ្រង់គង់លើអាសនៈដែលគេក្រាលនោះក្រាលហើយ លុះគង់ហើយទ្រង់លាងព្រះបាទ ។ ចំណែកលោកដ៏មានអាយុទាំងនោះក៏នាំគ្នាក្រាបថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់រួចហើយ អង្គុយនៅក្នុងទីសមគួរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះអង្គទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលអនុរុទ្ធទាំងឡាយ(១) អ្នកទាំងឡាយល្មមអត់ធន់បានឬទេ អ្នកទាំងឡាយល្មមប្រព្រឹត្តទៅបានស្រួលឬទេ

---

១ ព្រះអង្គទ្រង់ត្រាស់ហៅមិនសំដៅយកព្រះអនុរុទ្ធតែមួយអង្គទេ ទ្រង់ត្រាស់ហៅចំពោះព្រះតាមព្រះថេរៈទាំងបីព្រះអង្គ ។

กตฺวา ปิณฺฑาเกน น กิเลมถาติ ฯ ๑มธุนียนฺ ภก-
ฺวา ยาเปนียนฺ ภกฺขา น ตมยนฺ ภุญฺเช ปิณฺฑาเกน
กิเลมาเมาติ ฯ ภควา ปน เต อนุปุพฺพา สมฺปนฺนา สมฺโม-
ทมานา อวิโรธมานา ขีเรนปายาสา อญฺญมญฺญนฺ ปิย-
จกฺขูหิ สมฺปสฺสนฺตา วิหรนฺตีติ ฯ ตกฺขณ(๑) มยนฺ ภุญฺเช สม-
มปฺปา สมฺโมทมานา อวิโรธมานา ขีเรนปายาสา อญฺญมญฺญนฺ
ปิยจกฺขูหิ สมฺปสฺสนฺตา วิหรามาติ ฯ ยถาภตนฺ
ปน ตุมฺเห อนุปุพฺพา สมฺปนฺนา สมฺโมทมานา อวิโรธมานา
ขีเรนปายาสา อญฺญมญฺญนฺ ปิยจกฺขูหิ สมฺปสฺสนฺตา
วิหรถาติ ฯ ๙๘ ยญฺหิ ภนฺเต ฆโร โหติ ลาภา วต
เม สุลทฺธนฺ วต เม ยาหนฺ ฆรูเปหิ สตฺถุจาริหิ

---

๑. ม. ปาตฺตเกสุ ตเสฺวว ฉ วิสฺสชฺชิตนฺติ ฯ

អ្នកចាំងឡាយមិនលំបាកដោយបិណ្ឌបាតឬទេ ។ ព្រះថេរៈចាំង៣អង្គក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំល្មមអត់ធន់បាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំល្មមប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស មួ៉ាងទៀត យើងខ្ញុំមិនបានលំបាកដោយបិណ្ឌបាតទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរទៀតថា ម្នាលអនុរុទ្ធចាំងឡាយ ចុះអ្នកចាំងឡាយបានព្រមព្រៀងស្មោះសរមិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមកដោយភ្នែកជាទីស្រឡាញ់ដែរឬ ។ ព្រះអនុរុទ្ធក្រាបបង្គំទូលថា ព្រះករុណា យើងខ្ញុំចាំងនោះព្រមព្រៀងស្មោះសរនឹងគ្នាមិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមកដោយភ្នែកជាទីស្រឡាញ់បាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរទៀតថា ម្នាលអនុរុទ្ធចាំងឡាយ អ្នកចាំងឡាយបានជាព្រមព្រៀងស្មោះសរនឹងគ្នាមិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមកដោយភ្នែកជាទីស្រឡាញ់ ដូចម្តេចទៅ ។ ព្រះអនុរុទ្ធក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ក្នុងទីនេះខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះថា អាត្មាអញបាននៅជាមួយនឹងពួកបុគ្គលដែលប្រព្រឹត្តធម៌ដ៏ប្រសើរស្មើគ្នាបែបនេះ ហៅពេញជាលាភរបស់អាត្មាអញ អាត្មាអញហៅពេញជា

สงฺฆิ วิหารมีตา ตสฺส มยฺหำ กเถ ฯเมสุ อายสฺมเนฺต-
สุ เมตฺตำ กายกมฺมำ ปจฺจุปฏฺฐิตำ อาวิ เจว รโหา จ
เมตฺตำ วจีกมฺมำ เมตฺตำ มโนกมฺมำ ปจฺจุปฏฺฐิตำ อาวิ เจว
รโหา จ ตสฺส มยฺหำ กเถ ฯำ โหาติ ยนฺนูนาหำ
สกำ จิตฺตำ นิกฺกิเปยฺยำ ฯเมสำเยว อายสฺมนฺตำนำ จิตฺตสฺส
วเส วเตฺตยฺยนฺติ โส โข อหำ กเถ สกำ จิตฺตำ
นิกฺกิเปยฺยำ ฯเมสำเยว อายสฺมนฺตำนำ จิตฺตสฺส วเส
วตฺตามิ ญาณา หิ โข เต กเถ กายา ฯกญฺ ปณ
มญฺ จิตฺตนฺติ ฯ อายสฺมาปิ โข นนฺทิโย อา-
ยสฺมาปิ โข กิมฺพิลเถ ภควนฺตำ ฯตนาเภจ มยฺหำปิ โข
กเถ ฯำ โหาติ ลาภา วต เม สุลทฺธำ วต เม
โยหำ ฯวรูเปหิ สพฺรหฺมจารีหิ สงฺฆิ วิหารมีตา ตสฺส
ปยฺหำ กเถ ฯเมสุ อายสฺมเนฺตสุ เมตฺตำ กายกมฺมำ
ปจฺจุปฏฺฐิตำ อาวิ เจว รโหา จ เมตฺตำ วจีกมฺมำ เมตฺตำ
มโนกมฺมำ ปจฺจุปฏฺฐิตำ อาวิ เจว รโหา จ ตสฺส

បានស្រួលពេកហើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គតែងជំកល់កាយកម្មប្រកបដោយមេត្តាចំពោះលោកដ៏មានអាយុអម្បាលនេះ ទាំងទីចំពោះមុខនឹងទីកំចាំង ខ្ញុំព្រះអង្គ តែងជំកល់វចីកម្មនឹងមនោកម្មប្រកបដោយមេត្តា ទាំងទីចំពោះមុខនឹងទីកំចាំង សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះអាត្មាអញគួរជាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះវិញ សូមទ្រង់ព្រះមេត្តាប្រោស (លុះគិតដូច្នេះហើយ) ខ្ញុំព្រះអង្គក៏ជាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះទៅ សូមទ្រង់ព្រះមេត្តាប្រោស ឯកាយរបស់យើងខ្ញុំផ្សេងគ្នាក៏ពិតមែន ប៉ុន្តែចិត្តដូចគ្នាតែម្យ៉ាង ។ ឯព្រះនន្ទិយៈដ៏មានអាយុ ទើបព្រះកិម្ពិលៈដ៏មានអាយុក៏បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគទៀតថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនៅជាមួយនឹងពួកបុគ្គលដែលប្រព្រឹត្តធម៌ដ៏ប្រសើរស្មើគ្នាបែបនេះ ហៅពេញជាលាភរបស់អាត្មាអញ អាត្មាអញហៅពេញជាបានស្រួលពេកហើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គតែងជំកល់កាយកម្មប្រកបដោយមេត្តាចំពោះលោកដ៏មានអាយុអម្បាលនេះ ទាំងទីចំពោះមុខនឹងទីកំចាំង ខ្ញុំព្រះអង្គតែងជំកល់វចីកម្មនឹងមនោកម្មប្រកបដោយមេត្តា

มญฺเ กเร ฆโร เหาตุ ยญฺญตฺถาย สกฺก จิตฺต นิกฺขิปตุ
ฯเปฯ ยาว อายสฺมนฺตาน จิตฺตสฺส วเสน วตฺตติ
เสา เอว อห กเร สกฺก จิตฺต นิกฺขิปตุ ฯเปฯ
ยาว อายสฺมนฺตาน จิตฺตสฺส วเสน วตฺตติ ติ
เอว เตน กเรฺ กาย ปกฺก ปน มญฺเ จิตฺตนฺติ
ฆโร เอว มย กเรฺ สมฺปตฺต สมฺโภนตาน อาวุโสมาน
ทีเฆน กาลสฺส อญฺญมญฺ ปิย จกฺขูหิ สมฺปสฺสนฺตา
วิหรามาติ ฯ ภควา ปน เอว อนุสฺสรติ อปฺปมตฺตา
อาตาปิโน ปหิตตฺตา วิหรถาติ ฯ ตสฺมา ห มย กเรฺ
อปฺปมตฺตา อาตาปิโน ปหิตตฺตา วิหรามาติ ฯ ยถา-
กถ ปน ตุมฺเห อนุสฺสรถ อปฺปมตฺตา อาตาปิโน ปหิ-
ตตฺตา วิหรถาติ ฯ ฯ ส ภเรฺ อมฺหาก เยา ปมกฺ

ទាំងទីបំពោះមុខនឹងទីកំចាំង សូមទ្រង់ព្រះមេត្តាក្រោស ខ្ញុំព្រះអង្គនោះមាន
សេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះអាត្មាអញគួរដាក់ចិត្តរបស់ខ្លួនចេញ
ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះវិញចុះ សូមទ្រង់
ព្រះមេត្តាក្រោស ខ្ញុំព្រះអង្គនោះបានដាក់ចិត្តរបស់ខ្លួនចេញហើយប្រព្រឹត្ត
តាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះវិញ សូមទ្រង់ព្រះមេត្តាក្រោស
ឯកាយរបស់យើងខ្ញុំផ្សេងគ្នាពិតមែន ប៉ុន្តែចិត្តដូចគ្នាតែម្យ៉ាង សូមទ្រង់
ព្រះមេត្តាក្រោស ដោយហេតុយ៉ាងនេះហើយ បានជាយើងខ្ញុំព្រមព្រៀង
ស្មោះសរ មិនវិវាទគ្នាដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញ
ទៅមកដោយចក្ខុជាទីស្រឡាញ់បាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់
សួរថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយមិនបានប្រហែសធ្វេស
មានព្យាយាមដុតកំលេស មានចិត្តបញ្ជូនទៅត្រង់ខ្លះដែរឬ ។ ព្រះអនុរុទ្ធ
ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាក្រោស យើងខ្ញុំមិនបានប្រហែស
ធ្វេសទេ ហើយមានព្យាយាមដុតកំលេសនឹងមានចិត្តបញ្ជូនទៅត្រង់ ។
ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំង
ឡាយដែលឥតមានប្រហែសធ្វេស មានតែព្យាយាមដុតកំលេស មានចិត្ត
បញ្ជូនទៅត្រង់ តើយ៉ាងដូចម្តេច ។ ព្រះថេរៈទាំង ៣ អង្គក្រាបបង្គំទូលថា
សូមទ្រង់ព្រះមេត្តាក្រោស បណ្តាយើងខ្ញុំដែលនៅកងទីនេះ បើលោកណា

តាមតោ បិណ្ឌាយ បដិក្កមតិ សោ អាសនំ បញ្ញាបេតិ
ចាតោនកំ ចាតបីឋំ ចាតកថលិកំ ឧបដ្ឋិបតិ
អវក្ការចាតិំ ឆោរិត្វា ឧបដ្ឋាបេតិ ចាតិយំ បរិភោ-
ជនីយំ ឧបដ្ឋាបេតិ យោ បច្ឆា តាមតោ បិណ្ឌាយ បដិក្កមតិ
សចេ ហោតិ ភុត្តាវសេសោ សចេ អាកង្ខតិ ភុញ្ជតិ
ឆោ ចេ អាកង្ខតិ អបហរិតេ វា ឆឌ្ឌេតិ អបាណ-
កេ វា ឧទកេ ឱបិលាបេតិ សោ អាសនំ ឧទ្ធរតិ
ចាតោនកំ ចាតបីឋំ ចាតកថលិកំ បដិសាមេតិ
អវក្ការចាតិំ ឆោរិត្វា បដិសាមេតិ ចាតិយំ បរិភោ-
ជនីយំ បដិសាមេតិ ភត្តគ្គំ សម្មជ្ជតិ យោ បស្សតិ
ចាតិយយដ្ឋិំ វា បរិភោជនីយយដ្ឋិំ វា វច្ចយដ្ឋិំ វា រិត្តំ
តុច្ឆំ សោ ឧបដ្ឋាបេតិ សចស្សុ ហោតិ អាសយ្ហំ
ហត្ថវិការេន ឧក្កុយ្យ អាមឌ្ឌេត្វា ហត្ថវិលង្ឃកេន
ឧបដ្ឋាបេម ន ត្វេវ មយំ ភន្តេ តាបច្ចយា កិញ្ចិ កិច្ឆាប

ត្រឡប់មកពីបិណ្ឌបាតអំពីស្រុកមុនគេ លោកនោះរៀបចំគ្រាលអាសនៈ ដំកល់ទឹកសម្រាប់លាងដើង ដំកល់តាំងសម្រាប់ត្រដើង ដែលលាងរួច ទំាងដំកល់គ្រឿងសម្រាប់ត្រដើងដែលមិនទាន់លាង ហើយលាងភាជន៍ សម្រាប់ផ្ដេបាយដំកល់ទុកឲ្យស្រួល រួចដំកល់ទឹកឆាន់ទំាងទឹកប្រៃប្រាស់ លោកណាមកពីបិណ្ឌបាតអំពីស្រុកក្រោយគេ បើមានរបស់ដែលសល់ពីឆាន់ បើកិក្ខុនោះចង់ឆាន់ក៏ឆាន់ទៅ បើមិនចង់ឆាន់ទេ ចាក់ចោលទៅក្នុងទីគ្មានស្មៅស្រស់ក៏បាន ឬចសាចទៅក្នុងទឹកដែលគ្មានសត្វតូចក៏បាន រួចលោកនោះរើអាសនៈចេញ ហើយរៀបចំទុកជាក់ទឹកសម្រាប់លាងដើង តាំងសម្រាប់ត្រដើងដែលលាងរួចហើយ ទំាងគ្រឿងសម្រាប់ត្រដើងដែលមិនទាន់លាង ហើយលាងភាជន៍សម្រាប់ផ្ដេបាយរៀបចំទុកជាក់ រួចរៀបទុកជាក់ទឹកឆាន់ទំាងទឹកប្រៃប្រាស់ ហើយចាសពេងភត្ត បើលោកណាឃើញក្អមសម្រាប់ជាក់ទឹកឆាន់ក្តី ក្អមសម្រាប់ជាក់ទឹកប្រៃប្រាស់ក្តី ក្អមសម្រាប់ជាក់ទឹកលាងវិញ្ចៈក្តី រលើងសោះទេ លោកនោះក៏ដំកល់ទុកឲ្យមានឡើង បើលោកនោះមិនអាចលើកដោយកំឡាំងដៃបានទេ ក៏យើងខ្ញុំហៅភិក្ខុ (ឯទៀត) មកជាពីរបួនដួយលើកប្ដូរសែងដោយដៃយកទៅដំកល់ទុក សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំមិនបាច់បញ្ជូញវាចាព្រោះហេតុប៉ុណ្ណោះឡើយ សូមទ្រង់ព្រះមេត្តាប្រោស

ปญฺหาหิ กงฺขาวิตรณิยา นาม สพฺพญฺญุพุทฺธานญฺเญว สมตฺถา วิสยา น สาวกานนฺติ ฯ อยเมตฺถ สงฺเขปกถา ฯ วิตฺถารโต ปน สมนฺตปาสาทิกาย วินยฏฺฐกถาย ปาราชิกวณฺณนาย วุตฺตนยานุสาเรน เวทิตพฺพา ฯ

[๑๙๖] อยเมตฺถ ปาฬิมุตฺตกวินิจฺฉโย ฯ ตตฺถ ยสฺมา ปาราชิกสิกฺขาปทปริโยสาเน ปาราชิกาปตฺติ นาม ปาราชิกาย ปาราชิกาปตฺติ สงฺฆาทิเสสาย สงฺฆาทิเสสาปตฺติ ถุลฺลจฺจยาย ถุลฺลจฺจยาปตฺติ ปาจิตฺติยาย ปาจิตฺติยาปตฺติ ปาฏิเทสนียาย ปาฏิเทสนียาปตฺติ ทุกฺกฏสฺส ทุกฺกฏาปตฺติ ทุพฺภาสิตสฺส ทุพฺภาสิตาปตฺติ อนาปตฺติ นาม ปาราชิกาย ปาราชิกาปตฺติ สงฺฆาทิเสสาย สงฺฆาทิเสสาปตฺติ ถุลฺลจฺจยาย ถุลฺลจฺจยาปตฺติ ปาจิตฺติยาย ปาจิตฺติยาปตฺติ ปาฏิเทสนียาย ปาฏิเทสนียาปตฺติ ทุกฺกฏสฺส ทุกฺกฏาปตฺติ ทุพฺภาสิตสฺส ทุพฺภาสิตาปตฺติ สาปตฺติ นาม ปาราชิกาย ปาราชิกาปตฺติ สงฺฆาทิเสสาย สงฺฆาทิเสสาปตฺติ ถุลฺลจฺจยาย ถุลฺลจฺจยาปตฺติ ปาจิตฺติยาย ปาจิตฺติยาปตฺติ ปาฏิเทสนียาย ปาฏิเทสนียาปตฺติ ทุกฺกฏสฺส ทุกฺกฏาปตฺติ ทุพฺภาสิตสฺส ทุพฺภาสิตาปตฺติ สาปตฺติวุฏฺฐานนฺติ ฯ

ម្យ៉ាងទៀត តែគ្រប់ ៥ ថ្ងៃហើយ យើងខ្ញុំតែងអង្គុយប្រជុំគ្នាដោយធម្មីកថា អស់រាត្រីទាំងមូល(១) សូមទ្រង់ព្រះមេត្តាត្រាស ដោយហេតុយ៉ាងនេះ ហើយ បានជាយើងខ្ញុំព្រះអង្គឥតមានសេចក្តីប្រហែសឆ្អែស ខំព្យាយាម ជុតកិលេស មានចិត្តបញ្ជូនទៅត្រង់ ឥតមានទឹកនា (ដល់កាយទីងជីវិតឡើយ) ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ពន្យល់ព្រះអនុរុទ្ធដ៏មានអាយុផង ព្រះនន្ទិយៈដ៏មានអាយុផង ព្រះកិម្ពិលៈដ៏មានអាយុផង ឲ្យយល់ប្រយោជន៍ក្នុងបច្ចុប្បន្នទឹងបរលោក ឲ្យប្រតិបត្តិតាម ឲ្យខ្ជិយ្យាតក្នុងការកុសល ឲ្យរីករាយ ដោយធម្មីកថា រួចទ្រង់ក្រោកចាកអាសនៈហើយយាងទៅកាន់ចារិកប្រទេសចារិលេយ្យកៈ កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ក៏ចូលដល់ទៅប្រទេសចារិលេយ្យកៈ ។ ពុទ្ធា ព្រះមានព្រះភាគទ្រង់គង់នៅក្រោមម្លប់កន្ទុសាលព្រឹក្ស ក្នុងដងវៃព្រៃឈ្មោះរក្ខិតនាប្រទេសចារិលេយ្យកៈនោះ ។

(១៩៥) លោនោះ កាលព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងទីស្ងាត់សមំនៅក្នុងព្រៃកម្ពុជ ទ្រង់កើតមានព្រះហឫទ័យត្រិះរិះឡើងយ៉ាងនេះថា កាលពេលមុនតថាគតនៅច្រឡូកច្រឡំដោយពួកកិក្ខុទាំងនោះដែលនៅក្នុងក្រុងកោសម្ពីជាអ្នកធ្វើសេចក្តីបង្កហេតុ ធ្វើសេចក្តីឈ្លោះ ធ្វើសេចក្តីវិវាទ ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ មិនបានសេចក្តីសប្បាយ

---

១ គ្រប់ត្រាំរាត្រី តែងប្រជុំគ្នានិយាយធម៌អាចិអស់មួយរយៈ ។

ឯតរហិ ឯកោ អនុតិយោ សុខំ ជាសុ វិហរាមិ អញ្ញត្រែវ តេហិ កោសម្ពិកេហិ តិក្ខ្ខុហិ កណ្ហានការកេហិ កលហការកេហិ វិវាទការកេហិ កស្សុការកេហិ សង្ឃេ អធិករណការកេហីតិ ។ អញ្ញតរោបិ ខោ ហត្ថិទាយកោ អាកិណ្ណោ វិហរតិ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ(๑) ហត្ថិច្ឆាបេហិ(๒) ឯឆ្ចក្កានិ ចេវ តិណានិ ខាទតិ ជិវ្ហគ្គគ្គញ្ចស្ស សាខាភង្គំ ខាទន្តិ អារិលានិ ច ថានីយានិ បិវតិ ជិវ្ហគ្គាហញ្ចស្ស(๓) ជិវ្ហាឈ្លាស្ស ហត្ថិ. និយោ កាយំ ឧបនិយ្យំសន្តិយោ កច្ឆន្តិ ។ **អថខោ** តស្ស ហត្ថិទាយកស្ស ឯតទហោសិ អហំ ខោ អាកិណ្ណោ វិហរាមិ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ ហត្ថិច្ឆា. បេហិ ឯឆ្ចក្កានិ ចេវ តិណានិ ខាទាមិ ជិវ្ហគ្គគ្គញ្ចេ សាខាភង្គំ ខាទន្តិ អារិលានិ ច ថានីយានិ បិវាមិ

---

๑ ម. ហត្ថិកឡភេហិ ។ ๒ ហត្ថិច្ឆាបកេហិ ។ ๓ ម.ជិវ្ហគ្គគ្គញ្ច ។

កង់ពេលនេះ តថាគតតែម្នាក់ឯងគ្មាននរណាជាគំរប់ពីរ ហើយបានទៅជាទ្មី
សប្បាយ ព្រោះវៀរផុតអំពីពួកកិកូទាំងនោះដែលនៅកង់ក្រែងកោសម្ពីជា
អ្នកធ្វើសេចក្តីបង្កហេតុ ធ្វើសេចក្តីឈ្លោះគ្នា ធ្វើសេចក្តីវិវាទគ្នា ធ្វើតិរច្ឆាន-
កថា ធ្វើអធិករណ៍ក្នុងសង្ឃ ។ មានដំរីដ៏ប្រសើរ ១ នៅច្រឡូកច្រឡំ
នឹងពួកដំរីឈ្មោល ពួកដំរីញី ពួកដំរីស្ទាវ នឹងពួកកូនដំរីតូច ។ ហើយស៊ី
ស្មៅដែលពួកដំរី (មានដំរីឈ្មោលជាដើមនោះ) ចោចផ្តាច់ចុងចេញ ចំ-
ណែកខាងពួកដំរីទាំងនោះក៏ស៊ីមែកឈើចាក់ៗ ដែលដំរីដ៏ប្រសើរនោះកាច់
បំបាក់ខ្ទេចខ្ទីវិញ ឯដំរីដ៏ប្រសើរក៏ផឹកតែទឹកល្អក់ កាលបើដំរីដ៏ប្រសើរ
ដើរចុះទៅឯកំពង់ទឹក អស់ពួកមេដំរីក៏ដើរត្រដុសកាយ ។ ឯដំរីដ៏ប្រសើរ
នោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនៅច្រឡូកច្រឡំដោយពួក
ដំរីឈ្មោល ពួកដំរីញី ពួកដំរីស្ទាវ នឹងពួកកូនដំរីតូច ។ ហើយស៊ីស្មៅ
ដែលដំរីទាំងនោះចោចផ្តាច់ចុងចេញ ចំណែកពួកដំរីទាំងនោះក៏ស៊ីមែក
ឈើចាក់ ។ ដែលអាត្មាអញកាច់បំបាក់ខ្ទេចខ្ទីវិញ អាត្មាអញផឹកទឹកក៏ល្អក់

ตุฏฺฐหฏฺฐา[๑] เต ตุฏฺฐิสฺสา มหาตุฏฺฐิยา ตาย ขณิ-
ยา สนฺตุฏฺฐา ตฏฺฐนฺติ ยนฺนูนาหำ ฆโต ฯ ปณาเมฺห
ปุตฺตโก ฯ วิหารเยฺยสุ ฯ อถโข สา มาตุคามา
ยฺวา อปณฺฑิตา เยน ตาวิลเยฺยกำ รกฺขิตวนสณฺฑา
ตทุปสงฺกมิ ฯ อุปสงฺกมิตฺวา
สาณฺฑาย ตตฺถโต ตาณิยำ ปริโภคาณิยำ อุปฏฺฐาเปสิ
อปราปรำ ตเถว ฯ อถโข สา มาตุคามา
ฆตนฺเตนาสิ อหำ โข ปุเพฺพ อาตกิณฺณา ณ ชาสุ
วิหาสึ มาตุฏฺฐิ มาตุฏฺฐินิ มาตุตลเตนิ มาตุปฺปาเตนิ
ณิฏฺฐาณิ เตว ตณฺหาณิ ขาทึ ตุตฺตาตตฺตา เต สา-
ขาตฺถิ ขาทึสุ อาวิลาณิ ตถาณิยาณิ อถายึ ตุฏฺฐาหา
เต ตุฏฺฐิสฺสา มาตุฏฺฐิยา ตาย อุปณิยำ สนฺตุฏฺฐิยา
อตมฺสุ สาหุ ฆตนฺเตนาสิ ฆตนฺเตนาสิ ฆโต อนุตฺถิยา สุขำ ชาสุ
วิหาตุ อญฺญเตฺรว มาตุฏฺฐิ มาตุฏฺฐินิ มาตุตลเตนิ

๑ ม. ฆตนฺเตนาสิ ฯ

កាលបើអាត្មាអញដើរចុះទៅងងុំកំពង់ទឹក អស់ពួកមេដំរីក៏ដើរតែដុសកាយ បើដូច្នោះគួរអាត្មាអញថយចេញពីហ្វូងទៅនៅម្នាក់ឯងវិញចុះ ។ គ្រានោះ ដំរីដ៏ប្រសើរនោះដើរបែកចេញពីហ្វូងចូលទៅកាន់សំណាក់ព្រះដ៏មានព្រះភាគដែលទ្រង់គង់ក្រោមម្លប់កន្ទុសាលព្រឹក្សក្នុងដងព្រៃឈ្មោះកុតិ នាបារិលេយ្យកប្រទេស លុះចូលទៅដល់ហើយក៏ដំកល់ទឹកធានាន់ធំទឹកប្រែប្រាស់ដោយប្រមោយចំពោះព្រះដ៏មានព្រះភាគ ហើយធ្វើទឹកខ្ទេងនោះមិនឲ្យមានស្នៀស្រស់ផង ។ លំដាប់ពីនោះមក ដំរីដ៏ប្រសើរនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីដើមអាត្មាអញនៅច្រឡូកច្រឡំនឹងពួកដំរីឈ្មោល ពួកមេដំរី ពួកដំរីស្ទាវ នឹងពួកកូនដំរីតូច ។ ហើយអាត្មាអញបានស៊ីស្មៅដែលពួកដំរីទាំងនោះជ្រាបផ្តាច់ចុងចេញ ចំណែកខាងពួកដំរីទាំងនោះក៏បានស៊ីមែកឈើបាក់ ។ ដែលអាត្មាអញកាច់បំបាក់ខ្ចេចខ្ចីវិញមិនតែប៉ុណ្ណោះសោត អាត្មាអញបានទាំងធ្វើកទឹកល្អក់ កាលបើអាត្មាអញដើរចុះទៅងងុំកំពង់ទឹក ពួកមេដំរីក៏ដើរតែដុសកាយ ក្នុងពេលនេះអាត្មាអញតែម្នាក់ឯងឥតមាននរណាជាគំរប់ពីរ ហើយបានទៅជាសុខស្រួលបួល ព្រោះបានវៀរចាកពួកដំរីឈ្មោល ពួកដំរីញី ពួកដំរីស្ទាវ

ហន្តិ ជ្ជាបេហីតិ ។ អថខោ ភគវា អត្តនោ ច បរិវេកំ
វិទិត្វា តស្ស ច ហត្ថិនាគស្ស ចេតសា ចេតោបរិ-
តក្កមញ្ញាយ តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ឯតំ នាគស្ស នាគេន
ឧបសាទនិ្ទស្ស ហត្ថិនោ
សមេតិ ចិត្តំ ចិត្តេន
យេនេកោ រមតី វនេតិ ។

(๑๕๖) អថខោ ភគវា ចារិលេយ្យកេ យថាភិរន្តំ
វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្ពេន ចា-
រិកំ ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ ភគវា
សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

(๑๕๗) អថខោ ពោសម្ពិកោ[๑] ឧបាសកោ
ឯតទវោចិ ឥមេ ខោ អយ្យា ពោសម្ពិកា ភិក្ខូ
ពហុនោ អម្ហាកំ អនត្ថស្ស ការកា ឥមេហិ ឧញ្ញាទេ្ធ
ភគវា បក្កន្តោ ហន្ទ មយំ អយ្យេ ពោសម្ពិកេ ភិក្ខូ
នេវ អភិវាទេយ្យាម ន បច្ចុដ្ឋេយ្យាម ន អញ្ជលិកម្មំ

๑ ម. អថខោ ពោសម្ពិកា ឧបាសកា ឥមេ ភោតំ ទិស្សតិ ។

